សៀវភៅសិក្សា

# អំពី

# លទ្ធិប្រជាធិបតេយ្យ

១៩៥៦

ARCHIVES NATIONALES
COTE 7/210

រក្សាសិទ្ធិ

ថ្លៃ ១៥ រៀល

- Kram no 106 NS
- du 16-6-56.

# សៀវភៅសិក្សា

អំពី

# លទ្ធិប្រជាធិបតេយ្យ

ស្រង់ពីសារពត៌មានប្រជាជន

បោះផ្សាយលើកទី ១

# កថាមុខ

ហេតុដើមដែលនាំឲ្យយើងខ្ញុំមានសតិសម្បជញ្ញ រៀបរៀងនូវឯកសារលទ្ធិប្រជាធិបតេយ្យនេះឡើង គឺដោយយើងខ្ញុំយល់ថា រូបរបស់យើងខ្ញុំក៏មិនផ្សែកអ្វីអំពីពលរដ្ឋឯទៀត សុទ្ធតែមានឧត្តមគតិ ចង់ឲ្យលទ្ធិប្រជាធិបតេយ្យពិតៗបានស្ថាបនាឡើង ទុកជាមាគ៌ាសម្រាប់រដ្ឋកម្ពុជា ដើម្បីស្រោបស្រង់ជីវភាព មនុស្សជាតិឲ្យរស់នៅដោយសុចរិតយុត្តិធម៌នឹងសម្បូណ៌សប្បាយ ដោយស្របតាមឧត្តមគតិនៃពលរដ្ឋៗ ហើយលទ្ធិនេះទៀតច្រើនមានជនជំពូកខ្លះ គេឃោសនាបំប៉ែងឲ្យយើងវង្វេងភាន់ផង បានជាយើងខ្ញុំរៀបរៀងនូវឯកសារនេះឡើង សម្រាប់ជួយបំពេញថែមដល់មនោសញ្ចេតនានៃពលរដ្ឋឲ្យបានយល់មាគ៌ាប្រជាធិបតេយ្យពិតៗ ។ តែយើងខ្ញុំសូមសង្ឃឹមថា បើមានការខ្វះខាតដោយអត្ថន័យក្នុងផ្ទៃនៃឯកសាររបស់យើងៗមុខជានឹងបានទទួលនៅយោបល់ទិទៀន អំពីសំណាក់អស់លោកមិត្តភក្តិ អ្នកអានដោយសុទ្ធចិត្ត ដើម្បីកសាង

ឯកសារ (លទ្ធិប្រជាធិបតេយ្យ) នេះ ឲ្យបានថ្លៃថ្នូរបរិបូណ៌ ទាំងខាងតិកនិកនឹងអត្ថន័យជាងនេះទៅទៀត ។

ភ្នំពេញថ្ងៃទី ៦ កក្កដា ១៩៥៦

ស្រង់ពីសារពត៌មានប្រជាជន

បណ្ណាធិការ

ឈុម : បូជាឆំ

# បុព្វយោគ

មុនឆ្នាំ ១៩៥៤ ប្រទេសខ្មែរយើងបានឋិតក្រោមនឹមអាណានិគមនិយមបរទេសដ៏ធ្ងន់ធ្ងរ ម្ល៉ោះហើយប្រជាជនយើងបានស្គាល់តែអំណាចពេញទី នៃអ្នករាជការបារាំងខ្មែរ ៗ ការសង្កត់សង្កិនឥតត្រាប្រណី បាននាំឲ្យប្រជាជនទទួលតាំងខ្លួនជាខ្ញុំកញ្ជះគេ ពីព្រោះតែកាលណាយើងចង់ងើបតវ៉ាអ្វីបន្តិចឡើង កាលនោះត្រូវគេធ្វើទុក្ខទោសបង្ក្រាបឲ្យរញមរញូស្រពោនទៅវិញ ។ ម្នាក់ណារឹងទទឹងទឹងពន្ធអាករធ្ងន់ ឬទឹងក៏រំលោភអយុត្តិធម៌អ្នកនោះត្រូវគេចោទប្រកាន់ថាជាអ្នកបះបោរ, ជាមនុស្សទុរ្ជនត្រូវតែទទួលទណ្ឌកម្ម ៗ ដូច្នោះហើយយូរៗទៅ ក៏បែរជាសាំគេចខ្លួនទៅជាព្រមទទួលការមិនស្មើភាពក្នុងសង្គមជារបស់ធម្មជាតិទៅវិញ ព្រមទាំងដើម្បីបំពេរយើងឲ្យលង់ក្នុងទុក្ខវេទនានេះ អ្នកជិះជាន់សង្កត់សង្កិនបានបង្ហាត់បង្រៀនយើងឲ្យជឿសាសនា កំពះព្រេង, សំណាង ៗ ប៉ុន្តែក្នុងចំណោមមនុស្សចំនួនតូចមួយ ដែលបានរៀនសូត្រចេះដឹង, អ្នកជឿនលឿនខ្លះដែលច្រើនតែមានឫសកែវក្នុង

បណ្ដាអ្នករងទុក្ខទោស បានភ្ញាក់រលឹកឡើងឈឺចាប់ដោយឃើញអំពើអមនុស្សធម៌ ក៏សុខចិត្តទទួលធ្វើពលិកម្ម សព្វបែបសព្វយ៉ាង ដើម្បីសង្គ្រោះរំដោះទុក្ខឲ្យប្រជាជន និងខ្លួនដែលរងទុក្ខវេទនា ។ ទើបយើងសង្កេតឃើញមានការរំដួលតស៊ូដរាបមកក្នុងប្រវត្តិសាស្ត្រ នៃការស្ថាបនាឯករាជ្យជាតិខ្មែរ ពិសេសគឺការតស៊ូទប់ទល់ក្នុង ៨-៩ ឆ្នាំកន្លងមកនេះ ដែលបាននាំយកនូវកិច្ចព្រមព្រៀងនាក្រុងហ្សឺណែវ ជាលទ្ធផលបង្ហើយ ។

ដល់មកឆ្នាំ ១៩៤៧ ក្រោមការរុញច្រាននៃវីរបុរសយើងទាំងពីរនាក់មានទ្រង់ យុត្តិវង្ស និងលោក អៀវ-កើស, ប្រទេសខ្មែរជាលើកដំបូងបានទទួលរដ្ឋធម្មនុញ្ញសំរាប់គ្រប់-គ្រងប្រទេស ដូចអារ្យប្រទេសទាំងឡាយក្នុងពិភពលោក ។ ហើយក៏ដូច្នោះហើយ លទ្ធិប្រជាធិបតេយ្យតាំងបានផ្សាយជ្រួតជ្រាបដល់មហាជនភាគច្រើន ទាល់តែឥឡូវនេះក្នុងការប្រ-កួតរវាងគ្រប់គណបក្សនយោបាយដណ្ដើមកៅអីរដ្ឋសភា គេ

បានយកលទ្ធិប្រជាធិបតេយ្យ ( សុទ្ធឬក្រស្តនិយម ) ធ្វើជានុយឃោសនា ៗ យើងនិយាយនេះឥតបំផ្លើសសោះឡើយ ដូចបងប្អូនរួមជាតិបានឃើញបានជ្រាបស្រាប់ហើយតើ ក្នុង-សម័យឃោសនាបោះឆ្នោតកន្លងផុតទៅថ្មី ៗ នេះ អ្នកការពារលទ្ធិប្រជាធិបតេយ្យ (សុទ្ធ) និងអ្នកបង្កើតលទ្ធិប្រជាធិបតេយ្យ (ក្រស្តនិយម) បានតតាំងប្រឆាំងគ្នាយ៉ាងណាខ្លះ ៗ ថ្វីដ្បិតតែមានការអន្តរាយគួរឲ្យសោកស្តាយក្រៃពេកក្នុងបច្ចុប្បន្នកាល ប៉ុន្តែជាទីសង្ឃឹមទៅអនាគតកាល, ការណ៍មួយដែលគួរឲ្យពលរដ្ឋខ្មែរទាំងអស់គ្នា មិនថាខាងណាជាខាងណាក៏ដោយ ខាងចាញ់ឬខាងឈ្នះ កត់ចំណាំដោយទុកក្នុងចិត្តនោះគឺថាមហាជនខ្មែរពុំមានព្រងើយកន្តើយនឹងវាសនានៃប្រទេសយើងដូចពីលើកមុន ៗ នោះឡើយទេ ៗ ភស្តុតាង លើកនេះមានបងប្អូនរួមជាតិខ្លះដែលយើងកោតស្ញែងស្ងារតែរឹងប៉ឹង មិនបានញញើតអំពើសាហាវឃោរឃៅនៃពួកគេរវជនថោកទាប-ហ៊ានពុះពារឧបសគ្គរហូតដល់ខ្លះបាត់បង់ជីវិត ដើម្បីបំរើបុព្វ

ហេតុសុចរិត យុត្តិធម៌ ។

ដោយឃើញថា បច្ចុប្បន្នកាលនេះលទ្ធិប្រជាធិបតេយ្យទាក់អារម្មណ៍ខ្មែរពល់ប្រមិនរើសមុខ យើងមានសុទ្ធចិត្តនឹងលើកបញ្ហានេះយកមកពិនិត្យចងក្រងជាឯកសារឡើង ។ ត្រង់កន្លែងនេះ យើងគ្មានបំណងពិនិត្យបញ្ហាលទ្ធិប្រជាធិប-តេយ្យឲ្យល្អិតក្នុងនាទីយុត្តិធម្មសាស្ត្រទេ យើងប្រគល់ការៈនេះឲ្យទៅអ្នកឯកទេសចុះ ។ ចំណែកយើងត្រង់ចំណុចនេះយើងនឹងគ្រាន់តែនិយាយអំពីអង្គការសំខាន់ ៗ ដែលមានរូបក្នុងរដ្ឋហៅថាប្រជាធិបតេយ្យ ដូចជារដ្ឋសភា គណរដ្ឋមន្ត្រីនិងតុលាការ ។ ប៉ុន្តែយើងនឹងដេញដំណើរបញ្ហាលទ្ធិប្រជាធិប-តេយ្យទៅក្នុងនាទីនយោបាយនឹងទស្សនវិជ្ជាវិញពីព្រោះយើងចង់ឲ្យបងប្អូនរួមជាតិជ្រាបច្បាស់ អ្វីឯងដែលហៅថាលទ្ធិប្រជាធិបតេយ្យ? ហេតុអ្វីបានជាមានលទ្ធិប្រជាធិបតេយ្យ? លទ្ធិប្រជាធិបតេយ្យត្រូវមានវត្ថុធាតុអ្វីខ្លះទើបពេញលក្ខណៈបាន ? ប្រជាជនត្រូវសង្ឃឹមលើលទ្ធិប្រជាធិបតេយ្យដល់ត្រឹមព្រំដែន -

ណា ? សំនួរទាំងប៉ុន្មាននេះយើងទុកជាចាំបាច់ដល់ប្រជាជន ត្រូវបានជ្រាប ដើម្បីធ្វើជាមូលដ្ឋានសម្រាប់សកម្មភាពនយោបាយ ដែល ប្រជាជនត្រូវ តែអើពើជានិច្ចដើម្បីទឹងលើកដំកើង ជីវភាពរបស់ខ្លួនឲ្យបានខ្ពង់ខ្ពស់សមនឹងឋានៈជាមនុស្សសេរីស្មើភាព ដោយបំបាត់ការជិះជាន់សង្កត់សង្កិនអយុត្តិធម៌ ។

X X
X

# អំពីលទ្ធិប្រជាធិបតេយ្យ

កំណើតនៃលទ្ធិប្រជាធិបតេយ្យ.—វត្ថុនានាក្នុងលោកយើងនេះ ទោះមានរូបក្តី, គ្មានរូបក្តី, មានដំណើរជាធម្មជាតិ ដូចតទៅនេះដកប៖ កំណើត, ការវិវត្ត, ការប្រែក្លាយ ៗ ដូចវត្ថុជារូបី ដែលមានកើតឡើងហើយរស់នៅរួចវិនាសបាត់ទៅវិញ វត្ថុជាអរូបីមានចំណោះមនុស្ស គំនិតមនុស្ស លទ្ធិឬជំនឿសង្គមផ្សេង ៗ ជាដើម ក៏តែងតែមានដំណើរប្រែប្រួលជាច្បាប់ធម្មជាតិដូច្នោះដែរ ។ ហើយក្នុងការប្រែប្រួលជាធម្មជាតិនេះ វត្ថុមិនមែនចេះតែមានដំណើរតែពេញតែពាសទៅទេ គឺវាដើរតាមច្បាប់របស់វាជាដាច់ខាត ។ ឯច្បាប់នុះឯងហើយ ដែលយើងហៅថាច្បាប់ធម្មជាតិរបស់វត្ថុ ។ ច្បាប់នេះទៀតគេអាចស្គាល់គេអាចដឹង ប៉ុន្តែគេមិនអាចកែប្រែបានទេ ។ សារៈសំខាន់គឺ បើកាលណាយើងស្គាល់ច្បាប់នៃវត្ថុ ឬធាតុកូតណាមួយហើយ យើងអាចអនុវត្តច្បាប់ហ្នឹង ដើម្បីជាប្រយោជន៍ដល់សង្គមវិញបាន

ដូចជាឧទាហរណ៍ គេអនុវត្តច្បាប់ទម្ងន់វត្ថុ (វត្ថុទាំងឡាយ បើគ្មានទបសង្កត់ពាំងទេ តែងតែធ្លាក់ទៅក្រោមវិញ) ក្នុងការប្រើប្រាស់កម្លាំងកំពស់ទឹក ដែលធ្លាក់សម្រាប់ធ្វើឲ្យដើរម៉ាស៊ីនបង្កើតថាមពលអគ្គិសនីជាដើម ។ ការដឹងស្គាល់ច្បាប់ធម្មជាតិជាការចាំបាច់ណាស់ ដើម្បីឲ្យយើងនេះធ្វើការមិនដោយបំពានឲ្យយើងនេះ តម្រង់សកម្មភាពយើងទៅរកគោលបំណងយើងមួយដែលយើងដឹងជាក់ច្បាស់ថា យើងនឹងទៅដល់ឬមិនដល់ ដើម្បីជៀសវាងការរេរាយ អស់សង្ឃឹមឬសង្ស្រម ហួសហេតុ ហួសផល ដែលជាគុណវិបត្តិអន្តរាយគួរស្តាយមួយដែរ ។ ហេតុដូច្នេះដើម្បីឲ្យបានចំរើន យើងត្រូវពិនិត្យរៀនច្បាប់នៃបាតុភូតធម្មជាតិណាមួយដែលមានកើតឡើង ឲ្យស្គាល់លក្ខណៈរបស់វាច្បាស់ ស្គាល់ឫសកែវ, ស្គាល់ដំណើររបស់វាប្រាកដ ដើម្បីនឹងបញ្ជោរវា ឲ្យបំរើប្រយោជន៍យើង ។ យើងថាបញ្ជោរគឺបានន័យថា មិនមែនជំទាស់ញុលបំបាត់ស្រឡះទេ ។ ឧបមាៈ ទឹកទន្លេ

ស្ទឹង ព្រែក ហូរពីលើមកក្រោមតាមច្បាប់ នៃទម្ងន់វត្ថុដែល ធ្លាក់ពីខ្ពស់មកទាប បើកាលណាគ្មានឧបសគ្គពាំងទេ ៗ គេមិនអាចឃាត់ទឹកទន្លេស្ទឹងព្រែក មិនឲ្យហូរពុំបានជាដាច់ខាត វៀលែងតែបើគ្មានទឹកតែម្តង ៗ ប៉ុន្តែគេអាចនាំបង្វៀរផ្លូវទឹក បានដូចជាធ្វើទំនប់ ឬ ជីកព្រែកបង្ហូរចូលទៅក្នុងស្រែចំការ ស្រោចដំណាំដាំដុះ ដើម្បីយកផលានុផលសម្រាប់យើង ៗ នេះហៅថាចេះអនុវត្តច្បាប់ធម្មជាតិ ដើម្បីបំរើប្រយោជន៍យើង ៗ

ចុះអ្វីឯងទៅដែលនាំឲ្យវត្ថុមានដំណើរ ៖ កើត,វិវត្តប្រែក្លាយ? គេខំបង្រៀនយើងឲ្យឆ្លើយ ៖ ធម្មជាតិ ! ចុះអ្វីធម្មជាតិ ? គេខំពន្យល់យើងថា ធម្មជាតិគឺព្រះអាទិទេព ! ស្រួលណាស់ហ្ន៎ ! កាលបើទម្លាក់លើ ព្រះអាទិទេពទៅវាស្រេចទៅហើយ, មានអ្វីធំជាងព្រះអាទិទេពទៅទៀត នៅលើដីក្រោមមេឃនេះ!

វិទ្យាសាស្ត្រមិនយល់ព្រមស្រុះស្រួលនឹងការដោះស្រាយពាក់ក្រកែលយ៉ាងធុននេះទេ ៗ ផ្ទុយទៅវិញ វិទ្យា-

សាស្ត្របង្ហាញឲ្យឃើញថា ដំណើរនៃវត្ថុសុទ្ធតែមានមេនាំរបស់វាជាក់ស្តែង ៗ ដូចជាវត្ថុដែលមានជីវិត (រុក្ខជាតិ, សត្តជាតិ) មេនាំឲ្យរស់នៅ គឺការផ្លាស់វត្ថុធាតុចាស់ដែលស្លាប់ យកវត្ថុធាតុថ្មីដែលរស់មកជំនួស ៗ ឃើញថាមានការប្រយុទ្ធរវាងវត្ថុពីរផ្ទុយគ្នា៖ វត្ថុចាស់ស្លាប់ម្ខាង វត្ថុថ្មីរស់ម្ខាងទៀត ៗ វត្ថុពីរផ្ទុយគ្នានេះប្រយុទ្ធគ្នាយ៉ាងជិតស្និទ្ធក្នុងខ្លួនរបស់ដែលមានជីវិត នាំឲ្យរបស់នេះរស់នៅបាន ៗ កាលណាអស់ការផ្លាស់វត្ថុថ្មីមកជំនួសវត្ថុចាស់ក្នុងខ្លួនរបស់ណាមួយហើយ របស់នោះក៏អស់ជីវិតស្លាប់ទៅតាមដែរ ៗ យ៉ាងណាមិញ បាតុភូតិសង្គមធ្វើដំណើរបាន ក៏ដោយសារការប្រយុទ្ធរវាងវត្ថុធាតុថ្មី នឹងវត្ថុធាតុចាស់ផ្ទុយគ្នាដែរ ៗ ឯខ្លួននៃបាតុភូតិសង្គមគឺ សេដ្ឋកិច្ចនៃសង្គម បំណែកឯវត្ថុធាតុពីរផ្ទុយគ្នាក្នុងសង្គមនោះគឺ វណ្ណសង្គមពីរ៖ វណ្ណៈធ្វើអាជីវកម្ម, នឹងវណ្ណៈទ-ទួលរងអាជីវកម្ម ៗ អើ លទ្ធិប្រជាធិបតេយ្យ គឺជាបាតុភូតិសង្គមមួយ ៗ ដូច្នេះឯងលទ្ធិប្រជាធិបតេយ្យ ចាប់កំណើតក្នុងការ

ប្រយុទ្ធរវាងវណ្ណសង្គមនៅកាលបរិច្ឆេទណាមួយនៃដំណើរសេដ្ឋកិច្ចរបស់សង្គម ៗ និយាយមួយយ៉ាងទៅវិញ ការវិវត្តនៃសង្គមធ្វើឡើង អាស្រ័យដោយដំណើរសេដ្ឋកិច្ចនៃសង្គម ៗ ដូច្នេះក្នុងសង្គមនិមួយ ៗគឺសេដ្ឋកិច្ចនេះហើយជាឬសកែវ ដើម្បីពិនិត្យបញ្ហាសង្គម ៗ លទ្ធិ, ជំនឿ គំនិតផ្សេង ៗគឺជាផ្ទានផ្ទាងនៃសង្គមទេ រីឯសេដ្ឋកិច្ចវិញ វាជាសសរនៃសង្គម ៗ ហេតុនេះហើយបានជាបើចង់កុំឲ្យខុសភាន់ច្រឡំ ដើម្បីនឹងយល់ដ៏ត្រឹមត្រូវនូវលទ្ធិ ជំនឿ, ឬគំនិតមនុស្សនាកាលសម័យណាមួយយើងមិនត្រូវពិនិត្យលក្ខណា ផ្លូវចិត្ត ផ្លូវកាយនៃអ្នកនិពន្ធមេគំនិតនោះទេ យើងត្រូវពិនិត្យលក្ខណៈជាក់ស្តែងនៃសេដ្ឋកិច្ចក្នុងកាលសម័យនោះវិញទើបត្រឹមត្រូវប្រាកដ ៗ ត្រង់នេះយើងអាចយល់បានទៀតថា មិនមែនវីរបុរសណាម្នាក់ ៗ ទេដែលធ្វើប្រវត្តិសាស្ត្រជាតិ គឺពិតជាប្រជាជនទាំងមូលក្នុងក្របខណ្ឌនៃសេដ្ឋកិច្ចជាតិ ៗ ការប្រយុទ្ធរវាងវណ្ណៈផ្ទុយគ្នា នាំឲ្យមានការវិវត្តន៍ប្រែប្រួលនៃសង្គម ហើយដរាបណាតែមាន

វណ្ណៈផ្ទុយគ្នាក្នុងសង្គមគឺវណ្ណៈធ្វើអាជីវកម្ម នឹងវណ្ណៈទទួលរង អាជីវកម្ម គេមិនអាចបំបាត់ការប្រយុទ្ធរវាងវណ្ណៈបានឡើយ ពីព្រោះការប្រយុទ្ធនេះ មិនមែនមនុស្សធ្វើវាដោយចេតនាពេញចិត្តនោះទេ គឺដោយលក្ខណៈសម្បត្តិនៃសេដ្ឋកិច្ចជម្រុញហើយបង្ខំឲ្យធ្វើ ។ កម្មករក្នុងប្រទេសមូលធននិយមមិនមែនមានចិត្តសប្បាយចង់ធ្វើបាតុកម្មកូដកម្មទេ ។ ក្នុងពេលដែលមានការទាមទាររបៀបនេះម្ដងៗ កងប៉ូលិសនៃរដ្ឋាភិបាលមេទុនបាញ់កម្មកររបួសនឹងស្លាប់ជាច្រើននាក់ ប៉ុន្តែការរកចំណេញកប់ក្ដោងនៃមេទុននាំឲ្យកម្មករមិនតយុទ្ធមិនបាន ពីព្រោះបើទ្រាំនៅស្ងៀមទៅក៏គង់តែអត់បាយដាច់ពោះស្លាប់ដដែល ។ រឿងនេះគ្មានព្រះអាទិទេពឯណាជួយបានទេ ។ មានតែការរៀបចំសេដ្ឋកិច្ចទេ ហើយមានតែការរៀបចំសេដ្ឋកិច្ចប៉ុណ្ណោះឯង ទើបអាចនឹងសម្រេចបានលទ្ធផលល្អក្នុងរឿងនេះ ។ ឯការរៀបចំសេដ្ឋកិច្ចនេះទៀត គឺថាមិនមែនគ្រាន់តែកែសម្រួលទម្រង់ទៅហើយគ្រប់គ្រាន់នោះទេ គឺត្រូវផ្លាស់មូលដ្ឋានឫសកែវរបស់

វាទាំងស្រុង ពោលគឺការបង្កើតផលត្រូវបំបាត់អាជីវកម្មនៃ

មនុស្សធ្វើដោយមនុស្ស ។

១-សមាគមបុព្វកាលៈ មនុស្សដើមរស់នៅជាមួយ

គ្នាជាក្រុម ៗ ក៏ដូចជានាកាលជំនាន់យើងនេះ កុនកិច្ចផលិត

កម្មសម័យទំនើប ដើម្បីស្វែងរកជីវភាពខ្ពង់ខ្ពស់មនុស្សរស់នៅ

ជាមួយគ្នាជាសង្គម ដែលសមាជិកបែងចែកការងារគ្នាធ្វើ

នាសម័យបុព្វកាល មនុស្សប្រជុំគ្នាជាក្រុម បក្សសម្ពន្ធឬកុល

សម្ពន្ធ ដើម្បីប្រមូលកម្លាំងកាយការពារជីវិតតទល់នឹងការអត់

ឃ្លាន នឹងសត្វសាហាវ ឬនឹងធាតុក្នុងធម្មជាតិដូចជា ជំនន់

ទឹក ភ្លៀង ព្យុះ ។ល។ ការចិញ្ចឹមជីវិតនៃមនុស្សដើមប្រកប

ដោយបេះផ្លែឈើព្រៃ នឹងដេញសម្លាប់សត្វល្អិតតូច ៗ មាន

ក្ដាម ខ្យង គ្រំជាដើម ។ ឃើញថាការចិញ្ចឹមជីវិតរបៀបនេះ

មិនទៀងទាត់ទេ ។ ថ្ងៃនេះបេះបានផ្លែឈើច្រើន ឬចាប់បាន

ក្ដាមខ្យងច្រើន ថ្ងៃស្អែករកមិនបានក៏គ្មានអ្វីបំពេញក្រពះទៅ ។

ព្រោះតែលំបាកដូច្នេះហើយ បានជាមនុស្សដើមនៅជុំគ្នាជាក្រុមរួមសម្លាប់ៗ សមាជិកម្នាក់ៗចេញទៅរកអាហារបានមកយកទៅប្រគល់ឲ្យក្រុមទុកជាទ្រព្យរួម សម្រាប់សមូហភាព ៗ សមាជិកណារកមិនបានឯព្រៃត្រឡប់មកក្រុមវិញ បានទទួលផលរួមពីសមូហភាព ដើម្បីចំអែតពោះបំបាត់ឃ្លាន ៗ ក្រោយដែលគេចេះបង្កើតភ្លើងដោយសង្កៀតឈើនឹងឈើ, ឈើនឹងថ្ម ថ្មនឹងថ្ម, គេចេះចំអិនអាហារបរិភោគ ៗ បំណោះនេះបានរុញការស្វែងរកអាហារដល់ពួកព្រានប្រមាញ់ នឹងអ្នកនេសាទបណ្ដាលឲ្យគេចេះធ្វើធ្នូ នឹងប្រួញ ៗ ដល់ត្រឹមនេះ មានចែកការងារគ្នាធ្វើម្ដងរវាងសមាជិកក្រុម ៗ ការចែកការងារគ្នានេះបានធ្វើទៅតាមភេទ ៖ ប្រុស ៗ មានកម្លាំងពលំដាច់ចេញទៅបាញ់ឬនេសាទ, ស្រី ៗ ខ្សោយដាច់ចេញទៅបេះផ្លែឈើឬនៅចាំទីកន្លែង ៗ ប៉ុន្តែទោះយ៉ាងណាក៏ដោយ រហូតមកដល់នេះ សេដ្ឋកិច្ចនៃសមូហភាពចិតលើការយកពីធម្មជាតិ មិនលើការបង្កើតផលខ្លួនឯង

ទេ ៗ ម្ល៉ោះហើយបើក្នុងព្រៃក្តុងបឹងជិតខាង វិនាសអស់សត្វ អស់ត្រីកាលណា សមូហភាពត្រូវតែចាកចោលទីកន្លែងចាស់ ហួតហែង ទៅរកនៅទីកន្លែងថ្មីសម្បូណ៌ផងវិញ ៗ ដូច្នេះ លក្ខខណ្ឌសម្បត្តិសេដ្ឋកិច្ចមិនអាចនាំឲ្យមនុស្សជំនាន់នោះនឹកឃើញចង់បានកម្មសិទ្ធិឯកជនទេ ក្រៅអំពីកម្មសិទ្ធិចំពោះគ្រឿងប្រដាប់ប្រើប្រាស់ផ្ទាល់៖ ធ្នូ, ពូថៅ, លំពែង ៗ

២- សង្គមទាសភាពៈ ក្នុងកាលសម័យដាំដំណាំនិងចិញ្ចឹមសត្វ មានការផ្លាស់ប្តូរមួយសំខាន់ក្នុងសេដ្ឋកិច្ច ៗ សេដ្ឋកិច្ចលែងកើតពីការយកពីធម្មជាតិទៀតហើយសេដ្ឋកិច្ចបែរមកស្ថិតលើការបង្កើតផលវិញ ៗ គេទៅបាញ់ ឬទៅនេសាទមួយដងមួយយាមជាការកំសាន្តលំហែរ ឯការរកចិញ្ចឹមជីវិតមែន ៗ គឺដាំដំណាំនិងចិញ្ចឹមសត្វដែលគេផ្សាំងបាន ៗ នៅអំបុសសត្វដែលគេផ្សាំងមុនគេបង្អស់ គឺឆ្កែ ៗ នៅដើម យុគថ្ម (គឺសម័យដែលគេប្រើប្រដាប់ធ្វើអំពីថ្មមានពូថៅនិងលំពែង) គេផ្សាំងបានគោ-ចៀមរួចជ្រូក ហើយនៅចុង

សម័យដដែលនេះគេផ្សាំងបានសេះ ។

ការដាំដំណាំនិងការចិញ្ចឹមសត្វនាំឲ្យមានការប្រែប្រួលមួយធំក្នុងសង្គម ។ ពីដើមគេទៅរកអាហារពីព្រៃពីបឹងទន្លេដែលមានស្រាប់ ៗ ក្នុងធម្មជាតិ ។ ឥឡូវនេះគេចេះបង្កើតអាហារខ្លួនឯង ។ ការបង្កើតផលខ្លួនឯងដូច្នេះនាំឲ្យមនុស្សលែងខ្វល់ខ្វាយនឹងអាហារ ។ ម្យ៉ាងទៀតសេដ្ឋកិច្ចបង្កើតផលខ្លួនឯងនេះ នាំឲ្យមនុស្សបាននៅស្ថិតថេរត្រង់នាទីកន្លែងណាមួយ ៗ អ្នកដាំដំណាំមកតាំងផ្ទះសំបែងនៅទីវាលសម្បូណ៌ទៅដោយដីទំនេរមានជីជាតិ អ្នកចិញ្ចឹមសត្វតាំងលំនៅខ្លួននាដីជីភ្នំដែលសម្បូណ៌ទៅដោយស្មៅនិងរុក្ខជាតិតូច ៗ សំរាប់សត្វស៊ី ។ ការដាំដំណាំនិងចិញ្ចឹមសត្វនាំឲ្យបានផលលើសហួសពីការត្រូវការសម្រាប់ខ្លួនឯង ៗ ចាប់ពីនេះទៅការរស់នៅនៃជនមួយរូប ៗ មិនចាំបាច់ពឹងពាក់ជាដាច់ខាតលើសមាជិកឯទៀតនៃក្រុមទេ គេរកបានសេសសល់សម្រាប់ទុកទៅថ្ងៃក្រោយទៀតផង ។ ហើយក៏ដូច្នោះហើយ ក៏កម្ម-

សិទ្ធិចាប់មានកំណើតឡើង ៗ ផលដែលមានសេសសល់គេទុកសម្រាប់ប្តូរម្តង ៗ គេយកផលដំណាំទៅប្តូរនឹងសត្វដែលអ្នកឯទៀតចិញ្ចឹមឬផ្សុយមកវិញ គេយកទៅប្តូរនឹងគ្រឿងឧបករណ៍ផ្សេង ៗ ដែលការរស់នៅនឹងដំហរមួយកន្លែងអនុគ្រោះឲ្យធ្វើបានដើម្បីសម្រួលជីវភាព ដូចជាចក្រ ឆ្នាំង ក្អម ចាន កាំបិត ពូថៅជាដើម ៗ ចំណេញលក់ដូរក៏កើតមានឡើងជាលំដាប់ដែរ ៗ ការបង្កើតផលនេះប្រមូលទ្រព្យសម្បត្តិទៅនៅតែលើដៃពួកមេ ពួកនាយ ដែលកាន់តែលោភឡើង ៗ ៗ ហេតុដែលបង្កើតផលទៅហើយបាន។ ផលច្រើនយកមកទុកធ្វើជាទ្រព្យសម្បត្តិ, នាំឲ្យមេ ៗ ចង់បានមនុស្សមកធ្វើការឲ្យខ្លួន ៗ ដូច្នេះហើយពួកមេ ៗ នាំបង្កបង្កើតសង្គ្រាមរវាងកុលសម្ពន្ធដែលមានជំនឿផ្សេង ៗ អំពីគ្នា ៗ ម្តងនេះឈ្លើយសង្គ្រាម គេលែងសម្លាប់ចោលដូចពីមុន ៗ ទៀតហើយ គេយកឈ្លើយសង្គ្រាមមកធ្វើជាបាវព្រាវសម្រាប់ធ្វើការ កាប់គាស់ដីដាំដំណាំយកផលសម្រាប់គេវិញ ៗ សង្គមទាសភាពក៏ចាប់កំណើតឡើង ៗ

ដើម្បីបង្ខំឲ្យពួកទាសាធ្វើការកុំរឹងទទឹងនឹងម្ចាស់ទៅហើយ គេក៏ចាត់តាំងឲ្យមានអង្គការសំរាប់បង្ក្រាប ដោយកម្លាំងនូវពួកទាសាដែលបះបោរមិនព្រមធ្វើការ នេះគឺកំណើតនៃរដ្ឋ ។ ហេតុដូច្នេះសង្គមដែលមានរដ្ឋគ្រប់គ្រងដំបូងបង្អស់ គឺសង្គមទាសភាព ។

រដ្ឋស្ថិតក្រោមអំណាចមនុស្សម្នាក់គឺអធិរាជដែលប្រមូលផ្តុំក្នុងដៃរបស់ខ្លួន នូវអំណាចទាំងបីពោលគឺ នីតិប្រតិបត្តិ នីតិបញ្ញត្តិ, នឹងអំណាចតុលាការ ។ នីតិបញ្ញត្តិ នឹងអំណាចតុលាការគ្មានអង្គការរៀបរយជាស្ថាពរទេ ។ អំណាចនៃនីតិប្រតិបត្តិគ្របសង្កត់ទាំងអស់ ដោយកម្លាំងអាវុធនិងកងទ័ពទិញដោយទឹកប្រាក់ ឥតមានឧត្តមគតិទាល់តែសោះឡើយ ។

ក្នុងកិច្ចផលិតកម្ម ការទាក់ទងរវាងមនុស្សគឺម្ចាស់ និងបាវព្រាវ ។ ម្ចាស់មានទាំងអស់ ផ្ទះសម្បែង, ស្រែចំការ, គោក្របី;ប្រដាប់ប្រដាប្រើប្រាស ។ល។ បាវគ្មានអ្វីទាល់តែសោះក្រៅអំពីកម្លាំងកាយសម្រាប់ធ្វើការឲ្យម្ចាស់ ។ ជីវិតបាវ

ម្ចាស់ទុកដាក់តាមទំនើងចិត្ត នឹងសម្លាប់ពេលថ្ងៃណាក៏បាន រូបកាយគេលក់ដូរដូរពីម្ចាស់មួយទៅម្ចាស់មួយ ដូចគោក្របីដែរ ៗ សាច់ឈាមគេឥតមានត្រាប្រណី តែធ្វើការមិនពេញចិត្តគេ ៗ វាយដំជ្រាំជាក់បង្ខំឲ្យប្រឹងធ្វើឲ្យបានផលច្រើនដល់គេ ៗ អាស្រ័យការពាក់ទងរវាងមនុស្ស ក្នុងកិច្ចផលិតកម្មដូច្នេះហើយ បានជាការពលកម្មគេទុកជារបរថោកទាបជាទីបំផុត មានតែមនុស្សខ្ញុំគេដែរគេទេ ទើបធ្វើការពលកម្ម។ ក៏អាស្រ័យការពាក់ទងរវាងមនុស្សក្នុងកិច្ចផលិតកម្មដូច្នេះឯងដែរ បានជាសេដ្ឋកិច្ចពុំបានជឿនចំរើនទៅមុខសោះ ដោយហ្វូងសត្វដែលមានរូបកាយជាមនុស្ស គ្មានទឹកនាបចង់ស្រឡាញ់ការងារបន្តិចណាសោះឡើយ ធ្វើការព្រោះតែគេបង្ខំឲ្យធ្វើ ផលនៃកម្លាំងកាយខ្លួនបានទៅនៅតែលើដៃគេ, ធ្វើការមិនដឹងជាបានអ្វី បានតែសេចក្តីក្តៅក្រហាយឈឺចាប់ពិបាកវេទនា ៗ

ចំណែកឯពួកអ្នកម្ចាស់វិញសោត សប្បាយពេញចិត្ត

និងមានមនុស្សជាន់ថោកធ្វើការបំរើផ្ដល់ប្រយោជន៍ឲ្យខ្លួនដោយឥតបង់ខាតថ្លៃឈ្នួល គ្រាន់តែឲ្យស៊ីឲ្យរស់ ៗ ទៅបានហើយ គិតតែពីក្រេបជញ្ជក់សណ្ឋានភាពនេះ ដោយរីករាយសប្បាយគ្មានស្គាល់ទីបំផុត ឥតមានមកគិតរិះរកមធ្យោបាយជម្រុញសេដ្ឋកិច្ចឲ្យបានចំរើនឡើយ គិតតែបង្កើតបង្កើនកម្លាំងទ័ពទាហានសម្រាប់ថែរក្សាទុកនូវសណ្ឋានភាពនេះ និងសម្រាប់ធ្វើសង្គ្រាមចាប់ចងមនុស្សជាតិដទៃមកធ្វើជាបាវព្រាវ សម្រាប់ប្រើប្រាស់ខ្លួនឯងឬសម្រាប់លក់ដូរឯផ្សារ ដែលសម្រាប់លក់ទាសាដែលមានសម្បូណ៌នៅស្រុក ក្រេច រ៉ូម៉ាំង អាមេរិកកាំងជាដើម ។

ហេតុដែលពួកទាសាវេទនា ឥតបីប្រៀបដូច្នេះ នាំឲ្យពួកនេះបះបោរជាច្រើនលើក ច្រើនគ្រាដើម្បីបម្រះឲ្យរួចខ្លួនពីនឹមនៃការជិះជាន់ ។ ក្នុងប្រវត្តិសាស្ត្រនៃទាសភាពមានការបះបោរធំៗបីដងដែលគេឲ្យឈ្មោះថា «សង្គ្រាមនៃពួកទាសា»គឺសង្គ្រាមដែលជនរ៉ូម៉ាំង (ស្រុករ៉ូម៉ាំងជាស្រុកមួយធំរូកែជាងគេ

កន្លងសម័យនៃទាសភាព) បានធ្វើដើម្បីបង្រ្កាបពួកទាសាបះបោរ សង្គ្រាមទីមួយកើតនៅឆ្នាំ១៣៥ មុនគ្រឹស្តសករាជ ( ២០៩០ ឆ្នាំកន្លងមកហើយ) សង្គ្រាមទី២ កើតនៅឆ្នាំ ១០៥ មុន គ.ស. សង្គ្រាមទី៣ កើតនៅឆ្នាំ៧៣ គ.ស ។ នៅស្រុកប្រទេសឯទៀតៗក៏មានការបះបោរដូច្នេះដែរ ។ ការបះបោរខ្លះៗធ្វើអស់កំឡុង២ឬ៣ឆ្នាំក៏ពិតមែនហើយ ប៉ុន្តែវាគ្មានបានសម្រេចលទ្ធផលល្អដល់ពួកទាសាឡើយ ពីព្រោះលក្ខខណ្ឌសម្បត្តិសេដ្ឋកិច្ចសម័យនោះគ្មានអនុគ្រោះដល់ ។ ទាល់តែមកដល់សតវត្សទី១៩ ទើបទាសភាពបាត់បង់ទៅក្នុងលោក ៖ នៅក្នុងស្រុកអង់គ្លេស កាលនៃនិគមឡាសីទីមួយ (១៨២៥ -១៨៥៥) នៅប្រទេសបារាំង ហើយអាណានិគមអង់គ្លេសឆ្នាំ ១៨៣៣ នៅបណ្តាប្រទេសអាណានិគមបារាំង ឆ្នាំ ១៨៤៨ នៅសហរដ្ឋអាមេរិកឆ្នាំ ១៨៦៥ នៅប្រេស៊ិល ឆ្នាំ១៨៨៨ ។ នៅប្រទេសវៀតណាមយើង គេបំបាត់ទាសភាពឆ្នាំ១៨៨២ គឺថាក្រោយដែលអាណានិគមនិយមបារាំងចូលមកជិះជាន់ប្រទេសយើង (១៨៦៣) ។

កំឡុងយុគកណ្ដាល(៣៩៥-១៤៥៣)នៅបណ្ដាប្រទេស ដែលមានសេដ្ឋកិច្ចជឿនលឿន ដូចជានៅបណ្ដាប្រទេសជុំវិញសមុទ្រ «មេឌីទែរ៉ាណេ»ដែលអនុគ្រោះការពង្រីកជំនួញរវាងប្រទេសតាមផ្លូវទឹកទាសភាពក៏បានវិនាសទៅជាបណ្ដើរៗទៅហើយ ហេតុដែលនាំបំបាត់ទាសភាពគឺ របបទាសភាពមិនបានចំរើនដល់កិច្ចផលិតកម្ម ដែលបានរីកដល់ការបង្កើតផលដោយកម្មន្តសាល នឹងឧស្សាហកម្មតូច ៗ ទៅហើយ ៗ សភាពនៃសេដ្ឋកិច្ចថ្មីនេះវាផ្ទុយនឹងរបបទាសភាព ៗ សង្គ្រាមបំបាត់របបទាសភាពរវាងម្ចាស់ដីខាងជើងនឹងម្ចាស់ដីខាងត្បូងនៅស្រុកអាមេរិកកាំងឆ្នាំ ១៨៦១ គ្មានបុព្វហេតុអ្វីក្រៅពីសភាពការណ៍នេះទេ ពីព្រោះផ្លូវថ្មីនេះគេត្រូវការមនុស្សមានស្មារតីទទួលខុសត្រូវព្រមទាំងមានចំណេះវិជ្ជាខ្លះផង ទើបធ្វើការបានលទ្ធផលល្អ ៗ ឬឯពួកទាសាទាសីខ្វះលក្ខណសម្បត្តិទាំងអស់នេះទាំងស្រុង ពិបាកនឹងប្រើការក្នុងកម្មន្ត

សាល និងទស្សហាកម្មណាស់ ៗ បំណែកក្នុងផ្នែកកសិ-កម្មក៏ទៀតដែរ ប្រើទាសា-ទាសីមិនបានចំរើនសោះ ៗ គ្មានប្រយោជន៍អ្វីអាចជម្រុញឲ្យអ្នកធ្វើការទាំងនេះខំប្រឹងប្រែងសោះ ក្រៅពីដំបងព្រនង់ ពីព្រោះផលធ្វើបានទាំងប៉ុន្មានធ្លាក់ទៅលើដៃម្ចាស់ទាំងអស់ ៗ ម៉្លោះហើយក្នុងការតស៊ូនៃពួកទាសា-ទាសី ដើម្បីដោះខ្លួនធ្វើជាអ្នកជា ពួកម្ចាស់ក៏យល់ព្រមបណ្ដោយឲ្យបំបាត់ទាសភាព ៗ ប៉ុន្តែទាសាទាសីរួចបានតែសំបកខ្លួនទេ ដីស្រែសំបុកសម្បត្តិទាំងអស់នៅលើដៃម្ចាស់ ៗ មិនតែប៉ុណ្ណោះគេបង្ខំឲ្យទាសា-ទាសី ធ្វើការឲ្យគេដើម្បីលោះខ្លួនទៀតផង ៗ

ដូច្នេះការជិះជាន់ជញ្ជក់ឈាមអ្នកធ្វើការនៅដីដែលគ្រាន់តែបាត់ឈ្មោះថាទាសា - ទាសីតែប៉ុណ្ណោះ ដើម្បីយកឈ្មោះជាបាវខ្ញុំកំដរវិញ ៗ សង្គមថ្មីនេះគឺសង្គមសក្តិភូមិ ៗ

៣ - សង្គមសក្តិភូមិ៍ —; យើងបានឃើញលក្ខ

ខណ្ឌ ដែលមានអនុគ្រោះដល់ការបំបាត់ទាសភាព, ពោល គឺម៉្យាងសេចក្ដីទុក្ខវេទនា នៃពួកទាសា-ទាសី លំបាកឥត ឧបមាត្រាតែពួកនេះទ្រាំទ្ររបបនៃសង្គមទាសភាពពុំបាន - ម៉្យាងទៀតពាណិជ្ជកម្មក្នុងយុគកណ្ដាលដែលកាន់តែរីកទូ - លាយឡើងរវាងប្រទេស នាំឲ្យត្រូវការផលិតផលកាន់តែ ច្រើនឡើងសម្រាប់ផ្សារលក់ដូរ រីឯលក្ខន្តិកនៃពួកទាសា- ទាសីដែលជាអ្នកបង្កើតផល គ្មានអនុគ្រោះសោះដល់កិច្ច បំពេញផ្សារលក់ដូរនេះ ៗ ក៏ដូច្នេះហើយការតស៊ូនៃពួកទាសា ទាសីដើម្បីលោះខ្លួនឲ្យរួចជាអ្នកជាបានសម្រេចឡើង ៗ ការតស៊ូនេះដែលមានអ្នកបំរើនជួយឧបត្ថម្ភ ចល់នឹងពួកអ្នក - ម្ចាស់អភិរក្ស (អ្នកថែរក្សារបបចាស់) មិនមែនបានសម្រេច ដោយឥតលះបង់អាយុជីវិតសាច់ឈាមក៏ទេដែរ ៗ

សង្គមថ្មីដែលមកផ្លាស់សង្គមទាសភាពចាស់គឺសង្គមសក្តិ ភូមិដែលមានលទ្ធិអធិរាជដែលជារបបគ្រប់គ្រង ៗ ស្ដេច ជាប្រមុខរដ្ឋប្រកបទៅដោយសម្បូណ៌ាញ្ញាសិទ្ធិពេជ បន្ទាប់

មកមានដាក់សក្តិ ភូមិដែលជាម្ចាស់នៃដែនដីធំ ៗ ហើយដែលមានអំណាចដូចស្តេចគ្រងរដ្ឋដែនដីរបស់ខ្លួន ពោលគឺមានច្បាប់ មានតុលាការ មានពន្ធអាករ ដោយខ្លួន ១ គ្រប់ដែនដីនិមួយ ១ ដោយឡែក ៗ

ដោយហេតុថាទាសភាពត្រូវបានរំលាយទៅ ហើយមានមនុស្សកាន់តែច្រើនឡើងបានរំដោះខ្លួនពីខ្ញុំកំដរ គេមកធ្វើជាអ្នកជា ៗ អាស្រ័យហេតុនេះកម្មន្តសាលនិងសិប្បកម្មតូចតាចដើម្បីបង្កើតគ្រឿងឧបភោគបរិភោគ និងគ្រឿងប្រដាប់ប្រដាប្រើប្រាស់ល្មម ១ ដែលត្រូវការមនុស្សចំនួនច្រើនមកធ្វើជាកម្មករស៊ីថ្លៃឈ្នួល ក៏កាន់តែរីកធំឡើង ១ ជាលំដាប់ ៗ ក៏ប៉ុន្តែទោះយ៉ាងណាក៏ដោយ គេមិនទាន់មានសេរីភាពបរិបូណ៌ទេក្នុងរបររកស៊ីផ្សេង ១ ៗ ត្រូវមានច្បាប់ទម្លាប់អនុញ្ញាត និងបំពេញលក្ខណសម្បត្តិច្រើនជាន់ច្រើនថ្នាក់ ទើបធ្វើរបររកស៊ីណាមួយបាន ៗ របបនេះមានឡើង ដើម្បីនឹងធ្វើអនុគ្រោះផល់ជនដែលមានទ្រព្យ មានរបររកស៊ីរួចទៅហើយ ៗ ទប់មា

បីដូចជាដំណែងក្នុងរាជការគេទុកសម្រាប់តែអភិជន ( ជនដែលមានពូជអំបូរខ្ពង់ខ្ពស់ ) យ៉ាងណាមិញ មុខរបររកស៊ីទុកសម្រាប់ជនពួកខ្លះដូច្នោះដែរ ។ ម្ល៉ោះហើយអ្នកដែលរួចខ្លួនបានជាអ្នកជា គឺនៅទំនេរឥតការធ្វើ កាន់តែច្រើនឡើងៗ ។ ម្យ៉ាងទៀតផលិតផលដែលបង្កើតបានមកហើយ គេផ្សាយលក់ដូរជំទូលំទូលាយពុំបានទាស់មកអំពីមានពន្ធគយ អាករមាននៅគ្រប់ដំបន់ដែនដី គ្រប់ខែត្រដោយឡែកៗ និងធ្វើជំនួញទៅប្រទេសក្រៅក៏ជួបប្រទះនឹងឧបសគ្គច្រើនណាស់ដែរ ក្នុងការដឹកនាំកាត់ខែត្រដែលមានគយដោយខ្លួន ៗ ក្ដី ក្នុងការសុំច្បាប់អនុញ្ញាតិក្ដី ។ល។ សំបកសេដ្ឋកិច្ចបង្អៀតបង្អល់បែបនេះមិនអាចនឹងក្ដាប់ក្រសោបកម្លាំងសេដ្ឋកិច្ច ដែលកាន់តែរីកធំឡើង ៗ បានឡើយ ចាំតែដល់ពេលនឹងផ្ទុះបែកខ្ចាយចេញ ។ នៅវៀនប្រទេសអ្នកប្រាជ្ញ ( ដូចជា ហ្សង់ ហ្សាក់ រុស្សូនៅប្រទេសបារាំង ) ខំតាក់តែងទ្រឹស្ដីរកមធ្យោបាយដោះស្រាយបញ្ហាសង្គមស្មុគស្មាញតាមយោបល់របស់ខ្លួន ៗ ទាំងអស់គ្នា

តាមតារបបគ្រប់គ្រងដោយលទ្ធិប្រជាធិបតេយ្យ ។

មិនយូរប៉ុន្មាន ការរលំរបបចាស់បង្អៀតបង្អល់ត្រូវតែបានធ្វើឡើងជាការចាំបាច់ ដើម្បីនឹងបង្កើតរបបថ្មី បើកផ្លូវឲ្យសេដ្ឋកិច្ចអាចធ្វើដំណើរចំរើនទៅមុខទៀតបាន ។ ហើយបដិវត្តន៍ក៏កើតមានឡើង ។ គឺជាបដិវត្តន៍ធនិកបើកផ្លូវយ៉ាងធំឲ្យមូលធន ( ដើមទុន ) ដើរទៅមុខ ។ របបថ្មីដែលមកផ្លាស់ជំនួសរបបសក្តិភូមិផុតសម័យគឺរបបមូលធនិយម ។

៤ – សង្គមមូលធនិយម – ដូចយើងបានឃើញមករបបនេះ ត្រូវការធំបំផុតជាងគេនូវសេរីភាពខាងកិច្ចអាជីវកម្មនៃមូលធន ដើម្បីបង្កើតផលឥតមានព្រំដែន នឹងសេរីភាពក្នុងការលក់ដូរផលិតផលឥតឧបសគ្គធំដ៏ត្រឹមត្រូវ ។ ដើម្បីនឹងអនុវត្តនូវសេរីភាពនេះបាន បុគ្គលត្រូវមានសិទ្ធិផ្សេង ៗ គ្រប់គ្រាន់ ត្រូវមានសមភាពរវាងមនុស្ស ។ ដូច្នេះហើយអ្នកបដិវត្តន៍ដែលមានជ័យជំនះ ក៏ចាប់ប្រកាសនូវគោលការណ៍

មួយខាងក្រោមដែលគេទុកជាការចាំបាច់សម្រាប់សង្គមថ្មី៖

សមភាពនយោបាយ នឹងសង្គមក៏ដូចរវាងពលរដ្ឋទាំងអស់; គោរពនូវកម្មសិទ្ធិ; អធិបតេយ្យភាពនៃប្រជាជាតិ; សិទ្ធិនៃពលរដ្ឋទាំងអស់ដើម្បីកាន់ដំណែងរាជការសាធារណៈ: ភាគៗក៏ដូចបង្ខំឲ្យរាល់បុគ្គលគោរពច្បាប់ដែលជាធនៈរួមទូទៅ ; គោរពមតិនិងជំនឿផ្សេងៗ; សេរីភាពក្នុងការនិយាយ និងផ្សាយ; ពន្ធអាករដោយយុត្តិធម៌ទទួលបង់ដោយស្ម័គ្រចិត្ត ។ ដើម្បីនឹងអនុវត្តគោលការណ៍ទាំងនេះ គេរំលាយអភិជនភាព របបសក្តិភូមិ អង្គការ និងឋានន្តរៈទាំងឡាយណាដែលប៉ះពាល់ដល់សេរីភាព និងសមភាពនៃសិទ្ធិរវាងមនុស្ស ។

នេះហើយដែលហៅថា លទ្ធិប្រជាធិបតេយ្យ ។ លទ្ធិនេះចាប់កំណើតក្នុងសង្គមមូលធននិយម ។

X
X X

## អ្វីជាលទ្ធិប្រជាធិបតេយ្យ?

ហេតុដូចនេះលទ្ធិប្រជាធិបតេយ្យបានបង្កើតឡើង ដោយបណ្តា

កម្លាំងបង្កើតផលដែលទ្រាំទ្ររបបសេដ្ឋកិច្ចចាស់ បង្អៀតបង្អល់ ពុំបាន ។ កសិករ កម្មកររស់នៅដោយលំបាកវេទនា ទទួល រងអំពើអយុត្តិធម៌មួយពាន់មួយដំពូក ផងនិងខ្វះសេរីភាពក្នុងការ ធ្វើពាណិជ្ជកម្ម ក្នុងការបង្កើតផលដោយកម្មន្តសាលនិង ឧស្សាហកម្ម ៗ ដល់ទាំងពីរប្រភេទនេះរួមគ្នាបានជាភាគ ច្រើន ក្នុងប្រទេសក្រោកឡើង តយុទ្ធទល់នឹងអ្នកជិះជាន់ សង្កត់សង្កិនសក្តិភូមិ ដើម្បីរំលាយលទ្ធិចាស់ របបចាស់ តាំងបង្កើតលទ្ធិថ្មី របបថ្មី ៗ ក្នុងការតយុទ្ធនេះ ការដឹកនាំ ធ្លាក់ក្នុងដៃនៃពួកធនិក ព្រោះពួកនេះមានកម្លាំងអាវុធគ្រប់ គ្រាន់ ចំណែកឯកសិករ នឹងកម្មករមានតែខ្លួនចាំធ្វើតាមគេ ៗ ព្រោះហេតុដូច្នោះហើយបានជារបបថ្មី លទ្ធិថ្មី គឺរបបមូល ធននិយម នឹងលទ្ធិប្រជាធិបតេយ្យនុ៎ះឯង ៗ

«ប្រជា» ប្រែថារាស្ត្រទូទៅ «អធិបតេយ្យ» ប្រែថាមាន អំណាចជាធំ ៗ ពាក្យទាំងពីរមាត់នេះផ្សំគ្នាទៅបានជា ពាក្យ «ប្រជាធិបតេយ្យ» ប្រែថា រាស្ត្រមានអំណាចជាធំ ៗ

ដើម្បីនឹងអនុវត្តតាមលទ្ធិប្រជាធិបតេយ្យនេះឲ្យបានត្រឹមត្រូវ គេបានចាត់តាំងបង្កើតអង្គការសំខាន់ ៣ ដូចយើងទាំងអស់គ្នាបានដឹងស្រាប់គឺៈ រដ្ឋសភា (នីតិបញ្ញត្តិ) គណៈរដ្ឋមន្ត្រី (នីតិប្រតិបត្តិ) និងសាលាតុលាការជាន់ខ្ពស់ (អំណាចតុលាការ) ។ អំណាចសមត្ថភាព និងសកម្មភាពនៃអង្គការកំពូលទាំងបីនេះត្រូវប្រតិបត្តិឡើង ឲ្យស្របតាមគោលការណ៍នៃការកាត់បែកដាច់អំណាចពីគ្នា ដើម្បីនឹងជៀសវាងអំពើរំលោភ ដែលអាចនឹងមានឡើង បើអំណាចទាំងអស់ (អំណាចទាំងបី) មាននៅក្នុងដៃបុគ្គលតែម្នាក់ ឬអង្គការតែមួយ ។ ដូច្នេះអង្គការទាំងបីនេះប្រតិបត្តិការដាច់ឯកច្ឆានពីគ្នា មានសិទ្ធិអំណាចលើគ្នាទៅវិញទៅមកយ៉ាងណា ទាល់តែមានតុល្យភាពទប់កុំឲ្យមានការរំលោភម្ខាង ៗ ទៅរួច ។ យើងមិនដេញដោលឲ្យវែងឆ្ងាយទៅទៀតទេ ត្រង់ចំណុចយុត្តិធម្មសាស្ត្រ នៃបញ្ហាលទ្ធិប្រជាធិបតេយ្យនេះ ។ យើងបែរមកមើលចំណុចនយោបាយវិញ ក៏គង់តែត្រឹមនាទីណា ដែល

យើងត្រូវចាំត្រូវដឹងប៉ុណ្ណោះដែរអំពីរឿងនេះ ។

លទ្ធិប្រជាធិបតេយ្យត្រូវស្ថិតនៅលើគោល ការណ៍ ណាខ្លះ ? យើងឃើញមានគោលការសំខាន់បី គឺសេរីភាព, សមភាពនឹងយុត្តិធម៌ ។ ប៉ុន្តែក្នុងរបបមូលធនិយមដែលមកជំនួសរបបសក្តិភូមិចាស់ គោលការណ៍បីនេះមានន័យបានសេចក្តីជាដូចម្តេចខ្លះ ?

ក- សេរីភាព.- ដើមឡើយ សេរីភាព,សមភាពនឹងយុត្តិធម៌បានផ្តល់ឲ្យប្រជាជនគ្រប់ជាន់ថ្នាក់ មានកសិករកម្មករជាដើម ដែលទើបតែនឹងបំរះខ្លួនរួចពីការជិះជាន់នៃជនសក្តិភូមិអធិរាជ ។ ទោះយ៉ាងណាក៏ដោយ សេរីភាពសមភាពនឹងយុត្តិធម៌ សម្រាប់ប្រជាជនគ្រប់ជាន់ថ្នាក់ មានតែក្នុងក្បួនតម្រាច្បាប់ តាមហេតុការណ៍ជាក់ស្តែងជនទុគ៌តខ្សត់ខ្សោយ ពុំអាចទទួលអំណោយផលនៃវត្តមានតម្លៃទាំងនេះទេ ។ យ៉ាងណាមិញ គឺថាដូច្នេះ ៖ ឧបមាថាម្នាក់ៗ មានសេរីភាពក្នុងការនិយាយស្តី នឹងបោះពុម្ពផ្សាយនូវយោបល់ឬ

មតិរបស់ខ្លួន ៗ ដើម្បីនឹងប្រតិបត្តិសេរីភាពនេះបាន សាមី
ខ្លួនត្រូវមានមធ្យោបាយគ្រប់គ្រាន់ ទាំងខាងសម្ភារៈទាំងខាង
ចំរេះវិជ្ជា ៗ ម្ល៉ោះហើយកសិករនឹងកម្មករ ដែលរស់នៅ
ក្រីក្រលំបាកល្ងង់ខ្លៅ តាំងតែពីក្រោមការជិះជាន់នៃពួក
សក្តិភូមិមក ពុំអាចបំពេញបំណងខ្លួនបានឡើយ ៗ ជន
ធនិកដែលមានមធ្យោបាយបរិបូណ៌ ត្រេកត្រអាលនឹងហេតុ
ការណ៍ដែលមានដូចនេះណាស់ ៗ គេខំរក្សាសភាពនេះ
ដោយប្រណែនទុកអត្ថប្រយោជន៍សម្រាប់តែជាន់ថ្នាក់គេ ៗ
គេជាអ្នកកាន់កាប់កិច្ចការរដ្ឋ គេគ្មានគិតការពង្រីកការសិក្សា
គេគ្មានយកចិត្តទុកដាក់ខំសម្រួលការសិក្សា ធ្វើយ៉ាងណាឲ្យ
ជនទុគ៌តខ្សត់ខ្សោយ បានក្រេបរសជាតិនៃចំណេះវិជ្ជាទេ
គេទុកឲ្យល្ងង់ខ្លៅ ដើម្បីស្រួលជួលបានថោក យកមកប្រើ
ប្រាស់ដូចសត្វធាតុក្នុងកម្មន្តសាល ឧស្សាហកម្មរបស់គេ ៗ
បើមានអនុគ្រោះឲ្យចេះដឹងបន្តិចបន្តួច ក៏គ្រាន់តែសំរាប់ឲ្យ
ឯងវក់បុណ្យវក់សក្តិជិះជាន់គ្នាឯង បំរើប្រយោជន៍គេតែ

ប៉ុណ្ណោះ ៗ ចំពោះសេរីភាពក្នុងការជំនឿ ក៏មិនខុសគ្នាប៉ុន្មានដែរ ៗ អ្នកទុគ៌តខ្សត់ខ្សោយគ្មានសេរីភាពក្នុងការជំនឿទេ ឬក៏មានដែរតែសេរីភាពនោះត្រូវការរិតត្បិត ៗ ការជិះជាន់នៅសេរីភាពខាងជំនឿអាចធ្វើឡើងបានដោយផ្លូវពីរ ៖ ផ្លូវសង្គមកិច្ចនិងផ្លូវនយោបាយដោយកម្លាំង ៗ តាមផ្លូវសង្គមកិច្ចគេបាត់តាំងអង្គការសាកលដែលបានទទួលការឧបត្ថម្ភសព្វបែបសព្វយ៉ាងពីបក្សពួកគេជាន់ថ្នាក់គេ ដើម្បីផ្សាយលទ្ធិគេជំនឿគេគ្របសង្កត់លើលទ្ធិ លើជំនឿឯទៀត ៗ ដែលផ្ទុយនឹងប្រយោជន៍គេ ៗ ម្ល៉ោះហើយអ្នកដែលខ្វះមធ្យោបាយនឹងធ្វើដូចគេ ក៏បានឃើញលទ្ធិខ្លួនជំនឿខ្លួនស្វិតទៅ ៗ រួញទៅៗ រហូតដល់សាបសូន្យក៏មាន បើសិនណាជាលទ្ធិនោះ ឬជំនឿនោះគ្មានអនាគតពោលគឺគ្មានឬសកែវ គ្មានមូលដ្ឋានវិទ្យាសាស្ត្រ ៗ ឧទាហរណ៍ ដូចជាគ្រិស្តសាសនានិងជំនឿ ឬសាសនាតូចតាចឯទៀតៗ ៗ

តាមផ្លូវនយោបាយដោយកម្លាំង ត្រង់នេះរដ្ឋចូលមក

ក្នុងឆាកតែម្តង ៗ ដូចជានៅសហរដ្ឋអាមេរិក ប្រជាជនអាមេរិកកាំងគ្មានសេរីភាពនឹងជឿលទ្ធិកុម្មុយនិស្តទេ ៗ ជនណាដែលពជការ «ម៉ាក់ការទីស្ត» អាមេរិកកាំង សង្ស័យថាជាកុម្មុយនិស្តហើយ ជននោះត្រូវទទួលទណ្ឌកម្ម ៗ នៅអឺរ៉ុបដូចជានៅប្រទេសអង់គ្លេស ឬប្រទេសបារាំងជាដើម គេអនុញ្ញាតឲ្យមានគណៈបក្សកុម្មុយនិស្ត ប៉ុន្តែពជការរករឿងរកហេតុចោទប្រកាន់សព្វបែបសព្វយ៉ាងដើម្បីពិឃាតលទ្ធិកុម្មុយនិស្ត ៗ អើ! សេរីភាពក្នុងការជំនឿនិងសេរីភាពក្នុងការនិយាយស្តីបោះពុម្ពផ្សាយជាសេរីភាពសំខាន់បំផុត ក្នុងរបបប្រជាធិបតេយ្យ ហេតុដូច្នេះហើយបានជាហៅសេរីភាពខាងលើនេះថា «សេរីភាពប្រជាធិបតេយ្យ» ៗ

ដូច្នេះបើប្រសិនណាខ្វះសេរីភាពខាងជំនឿ ឬសេរីភាពខាងបោះពុម្ពផ្សាយ គេមិនអាចសន្មតថាមានលទ្ធិប្រជាធិបតេយ្យបានជាដាច់ខាត ៗ ព្រោះហេតុនេះហើយទើបប្រជាជនត្រូវដកល់ទុកជាករណីយកិច្ចប្រសើរជាងនៅទៀត ត្រូវដកល់ទុក

ជាកាតព្វកិច្ចផ្ទាល់ខ្លួននៅកិច្ចការពារយ៉ាងម៉ឺងម៉ាត់ នៃសេរីភាពទាំងពីរខាងលើនេះ (សេរីភាពខាងជំនឿនិងសេរីភាពខាងនិយាយស្តីបោះពុម្ពផ្សាយ) បើប្រជាជននោះស្រឡាញ់ចង់បានលទ្ធិប្រជាធិបតេយ្យពិត ៗ ។

ដរាបណាមានការបំពារំលោភលើសេរីភាពប្រជាធិបតេយ្យ ដរាបនោះត្រូវតែមានការតស៊ូតវ៉ាប្រឆាំងទល់មកវិញ ។

១.!· សមភាព: លក្ខណៈចារឹកនៃលទ្ធិប្រជាធិបតេយ្យមួយទៀតគឺសមភាព ។ ចំពោះសមភាពនេះប្រជាជនត្រូវយល់ដូចម្តេចខ្លះ ? គំនិតមួយដំបូង គឺសមភាពរវាងភេទទាំងពីរ ៖ សមភាពរវាងភេទបុរសនិងភេទស្ត្រី ។ បានសេចក្តីថា: បើបុរសមានសិទ្ធិនឹងធ្វើអ្វីបាន ត្រូវតែបើកសិទ្ធិឲ្យស្ត្រីធ្វើដូចគ្នាបានដែរ ។ ឧទាហរណ៍ ៖ ស្ត្រីត្រូវមានសិទ្ធិដូចបុរសនឹងកាន់តំណែង~~សំខាន់~~ក្នុងការតាំងពីនិយោជិតធម្មតារហូតដល់រដ្ឋមន្ត្រី ស្ត្រីមានសិទ្ធិបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឬឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រដូចបុរស ។ល។ សព្វថ្ងៃនេះ នៅ

គ្រប់អារ្យប្រទេសនានាគេមិនជំទាស់នឹងសមភាព រវាងគេទៀតទេ ។ ប៉ុន្តែនៅមានសមភាពរវាងមនុស្សលោកមួយយ៉ាងទៀត ដែលនៅមានអ្នកទ្រឹស្តីក្នុងប្រទេសខ្លះមិនទាន់ព្រមទទួលស្គាល់នៅឡើយ គឺសមភាពរវាងសាសន៍ ។ គេនៅប្រកាន់ថាសាសន៍នេះជាសាសន៍ខ្ពង់ខ្ពស់ សាសន៍នោះជាសាសន៍ថោកទាប ដូចជាថាសាសន៍ស្បែកសជាសាសន៍ថ្លៃថ្នូរ ចុះបន្ទាប់មកមានសាសន៍ស្បែកលឿង រួចស្រទាប់ក្រោមបង្អស់មានសាសន៍កំសត់ស្បែកខ្មៅ ដែលគេទុកជាសាសន៍ខ្ញុំកំដរគេ ។

យើងគ្មានបំណងនឹងពិនិត្យទ្រឹស្តីសាសន៍និយមទេ វាទូលាយហួសក្របខណ្ឌនៃឯកសារយើង ។ យើងគ្រាន់តែសូមរំឭកថា: សាសន៍និយមគឺជាលទ្ធិមួយដែរ បើដូច្នេះដើម្បីនឹងយល់លទ្ធិសាសន៍និយមនេះ យើងត្រូវពិនិត្យក្នុងរង្វង់នៃសេដ្ឋកិច្ច ឬសកែវាដុះក្នុងដីជាតិនៃកិច្ចផលិតកម្ម ។

ឥឡូវនេះយើងត្រឡប់មកមើលសមភាពវិញ ។ យើងដឹង

បានជាសមភាពដែលត្រូវមានដំបូងបង្អស់ក្នុងប្រជាជាតិនិមួយៗ គឺសមភាពរវាងភេទប្រុសនិងភេទស្រី ។ រួចទើបមានសិទ្ធ មួយទោទៀងៈ សមភាពត្រូវមានក្នុងនាទីណាខ្លះ ហើយក្នុងនាទីនិមួយៗសមភាពស្ថិតនៅលើអ្វី? យើងឃើញមាននាទីពីរ៖ នយោបាយនិងសង្គមកិច្ច ។ តាមន័យនយោបាយសមភាពស្ថិតនៅលើសិទ្ធិនៃមនុស្ស ។ ក្នុងរបបប្រជាធិបតេយ្យដែលយើងកំពង់តែពិនិត្យនេះ យើងឃើញមានសិទ្ធិសំខាន់ៗបី ៖

១– សិទ្ធិនៃពលរដ្ឋម្នាក់ៗ ដើម្បីកាន់តំណែងរាជការសាធារណៈ លទ្ធិប្រជាធិបតេយ្យគ្មានផ្អែកលើអ្វីក្រៅអំពីគំរោវិជ្ជានិងសមត្ថភាព នៃសាមីខ្លួនទេ ក្នុងការរើសយកអ្នកកាន់តំណែងរាជការ ។ ការប្រកាន់ប្រុសឬស្រី ការយោគយល់មុខឬមិត្រភក្តិ ការប្រកាន់បក្សពួកទើបប្រគល់តំណែងរាជការឲ្យមិនស្របនឹងលទ្ធិប្រជាធិបតេយ្យដល់តិចណាសោះ ។ មិនតែប៉ុណ្ណោះ ការរើសអើងដូច្នេះ នាំតែបំបែកប្រជាជាតិជាបក្សពួកជាមិត្រជាសត្រូវ ដែលជាហេតុនាំឲ្យអន្តរាយបំផុត

ដល់សាមគ្គីជាតិទាំងមូល ។ ហើយអ្នកដែលកាន់អាកប្បកិរិ-
យាដូច្នេះ តែងតែសង្ឃឹមលើកម្លាំងពួកក្បាល ដោយទាហាន
ប៉ូលិស គុកច្រវ៉ាក់ ដើម្បីទឹងពង្រីកអំណាចខ្លួន ។ អំពើនេះផ្ទុយ
ស្រឡះនឹងលទ្ធិប្រជាធិបតេយ្យ ។

២ – សិទ្ធិនៃពលរដ្ឋដើម្បីមានការងារធ្វើ ពលរដ្ឋម្នាក់ៗ
ត្រូវមានសិទ្ធិស្មើគ្នា ដើម្បីមានការងារធ្វើសមតាមតម្រិះវិជ្ជា
តាមសមត្ថភាព ។ រាជការត្រូវតែទំនុកបម្រុងពលរដ្ឋទាំងអស់
គ្នា មិនប្រកាន់ថាអ្នកនេះជាកូនចៅឯកឧត្តមនេះ ឬលោកនុះ
ទើបជួយឧបត្ថម្ភ ចំណែកកូនចៅអ្នកកម្មករឬកសិករមិនអើពើ
ទេឡើយ ។ បើទំនុកបម្រុងដោយរើសមុខដូច្នេះ សន្មតិបាន
ថាគ្មានលទ្ធិប្រជាធិបតេយ្យឡើយ ។

៣ – សិទ្ធិនៃពលរដ្ឋដើម្បីប្រាស្រ័យចូលក្នុងកិច្ចការ
ប្រយោជន៍រួមទៅកិច្ចការដែលរាជការសាធារណៈ ធ្វើទាំង
អម្បាលម៉ាណ ប្រជាជនទាំងមូលទទួលផលអំណោយផល
ទោះល្អក្តី អាក្រក់ក្តី ។ ហេតុដូច្នេះ លទ្ធិប្រជាធិបតេយ្យ

គម្រោងឲ្យពលរដ្ឋម្នាក់ៗ មានសិទ្ធិស្មើគ្នាក្នុងការគិតគូរដល់
ប្រយោជន៍រួមៗ កម្មករ កសិករ ឬអ្នកបង់ពន្ធម្នាក់ណាទៀត
ត្រូវមានសិទ្ធិនេះស្មើនឹងឯកឧត្ដមៈ រដ្ឋមន្ត្រី ឬតំណាងរាស្ត្រដែរ
យើងលើកយកឧទាហរណ៍ជារូបមួយមកបញ្ជាក់រឿងនេះ ៗ
ដូចជាបញ្ហា ជំនួយយោធាអាមេរិកាំង ដែលកំពុងតែធ្វើឲ្យ
ប្រជាជនយើង ព្រួយបារម្ភគ្រប់គ្នាចំពោះអនាគតនៃប្រទេស
យើង ៗ ជំនួយយោធាអាមេរិកាំងនេះ នាំផ្ដល់អំណោយ
ផល ទោះល្អក្ដី អាក្រក់ក្ដី ទៅដល់ប្រជាជាតិខ្មែរទាំងមូល
មិនថាជាន់ថ្នាក់សង្គមណាទេ ៗ ដូច្នេះ ជំនួយយោធាអា-
មេរិកាំងជាបញ្ហាដែលមានប្រយោជន៍រួមទូទៅ ហើយក៏ព្រោះ
ហេតុនេះហើយ ពលរដ្ឋខ្មែរគ្រប់រូបត្រូវមានសិទ្ធិនឹងបញ្ចេញ
មតិខ្លួនអំពីរឿងនេះ ដើម្បីឲ្យអ្នកទទួលខុសត្រូវ មានរដ្ឋ-
សភាក្រុមប្រឹក្សាព្រះរាជអាណាចក្រ និងគណៈរដ្ឋមន្ត្រីសំរេច
ឲ្យបានប្រកបតាមឆន្ទៈនៃភាគច្រើន ៗ តាមរបបប្រជាធិប-
តេយ្យ ពលរដ្ឋម្នាក់ៗ មានមធ្យោបាយច្រើនយ៉ាង ដើម្បី

សម្តែងនៅមតិខ្លួន ៖ អត្ថបទចុះផ្សាយតាមទំព័រកាសែត សំបុត្រ ឬញត្តិផ្ញើចំពោះទៅរដ្ឋសភាជាតិ ឬគណៈរដ្ឋមន្ត្រីពិនិត្យមើល ឬពិភាក្សាជួយយោបល់គ្នា ។ល។ *

ចុះតាមន័យសង្គមកិច្ចយើងត្រូវយល់សមភាពដូចម្តេច? ក្នុងរបបប្រជាធិបតេយ្យ? យើងឃើញមានពីរនាទី៖

១ – សមភាពក្នុងឋានៈជាពលរដ្ឋ បុគ្គលខ្មែរម្នាក់ៗ — ទោះបុរសក្តី ស្ត្រីក្តីជាពលរដ្ឋខ្មែរម្នាក់ ៗ ហេតុដូច្នេះខ្មែរត្រូវមានការគោរពគ្នាទៅវិញទៅមកមិនប្រកាន់ឋានៈនៃស្ថានភាពសង្គម ដរាបណាតែយើងរស់នៅដោយសុត្រង់ មិនប្រកបរបររកទទួលទានដោយទុច្ចរិតឬអមនុស្សធម៌ ។ អ្នករាជការនាម៉ឺនមន្ត្រីតូចធំត្រូវគោរពរាប់រកប្រជានុរាស្ត្រ ក៏ដូចជាផ្ទុយទៅវិញ ប្រជានុរាស្ត្រត្រូវស្រឡាញ់គោរពអ្នករាជការទាំងឡាយ ព្រោះថាសាមគ្គីភាព នឹងកិច្ចបដិសណ្ឋារៈទៅវិញទៅមកនាំឲ្យមានសហប្រតិបត្តិការប្រសើរណាស់ ក្នុងការកសាងប្រទេស ឲ្យបានចំរើនថ្កុំថ្កើងរុងរឿងទៅអនាគតកាល

ឲ្យតាន់សម័យនៃប្រទេសមានអារ្យធម៌ខ្ពង់ខ្ពស់ ៗ នេះហើយ គឺជាដើមគំនិតដំបូងនៃលទ្ធិប្រជាធិបតេយ្យចំពោះរឿងនេះ ៗ កប៉ុន្តែរបបមូលធនិយម ដែលផ្អែកលើកិច្ចអាជីវកម្មនៃមនុស្ស ធ្វើដោយមនុស្ស មិនអាចឲ្យសម្រេចគោលការណ៍ល្អប្រពៃនេះបានទេ ៗ ការទាក់ទងរវាងមនុស្សក្នុងកិច្ចផលិតកម្មមូលធនិយមនាំឲ្យមនុស្សមិនទុកចិត្តមនុស្ស នាំឲ្យមនុស្សខ្លាចមនុស្ស នាំឲ្យមនុស្សមើលងាយមើលថោកមនុស្ស ៗ ស្រួលងាយយល់ណាស់ អ្នកស្ទួរទេស្សហាករមេទុនម្នាក់លរមើល គេមុខជាទឹងឆ្លើយតបមកអ្នកវិញថាៈ ? កម្មករជាបាវរបស់ខ្ញុំ រស់ដោយសារខ្ញុំ ខ្ញុំចង់ដេញវាចោលក្នុងពេលណាក៏បាន ៗ អ្នកចង់ឲ្យខ្ញុំលើកស្ទួយវាស្មើមុខនឹងខ្ញុំឯណាបាន, ម្ដេចបាន ?

ហេតុដែលមានមនុស្សមួយក្រុម មានជាទ្រព្យនៅប្រដាប់ប្រដាសម្រាប់បង្កើតផលទាំងអស់; មនុស្សមួយក្រុមទៀតពុំគោដិលានអ្វីមាន តែកម្លាំងកាយសម្រាប់បង្កើតផលឲ្យគេ, ចិញ្ចឹមក្នុងខួរក្បាលមនុស្សនៅគំនិតមិនសមរម្យគេ

គ្នាទៅវិញទៅមកៗដើម្បីទំនងមើលជម្ងឺសង្គមនេះពួកមេទុនដែល កាន់កាប់ការគ្រប់គ្រង ប្រទេសរំចំរាញ់ខុសឋមួយមុខដែល គេបំពោកពេញទាំងសាលាសិក្សាជាតិតាំងពីកុមារដ្ឋាន រហូតមហាវិទ្យាល័យតែឥតបានលទ្ធផលល្អសោះ ហើយព្រោះហេតុអ្វី ? ខុសឋនោះគឺធម្មក្រិត្យាប្ដូរបរិយាសាស្ត្រប្ដូរអ្វី ១ មួយពាន់មួយបំពូកទៀតបែបផុននេះ ៗ គេមិនលាងគំនិតពីខួរក្បាលមនុស្សបានទេ បើគេមិនរំលើងបំបាត់ឬសកែវ សម្ភារៈនៃគំនិតនោះ ការអប់រម្យតាមផ្លូវចិត្តនឹងបានទទួលផលល្អតែកាលណាលក្ខខណ្ឌសង្គមមានអនុគ្រោះផង ៗ

២– សមភាពក្នុងផលិតកម្ម: សមភាពនេះបានន័យថា : អ្នកណាបានបង្កើតផលប៉ុន្មានត្រូវទទួលផលប៉ុណ្ណោះ ៗ គោលការណ៍នេះសុចរិតណាស់, សមហេតុសមផលណាស់, ជាមនុស្សធម៌ណាស់ ៗ ធ្វើបានប៉ុន្មានត្រូវបានប៉ុណ្ណឹង ៗ ប៉ុន្តែយើងសង្កេតមើលទៅក្នុងសង្គមមូលធនិយមយើងពុំបានឃើញដូច្នោះទេ ៗ ពួកមេ

ទុនដែលមានសព្វមានគ្រប់ ប្រើមធ្យោបាយជញ្ជក់ញើស-ឈាមនៃអ្នកកម្មករ ដើម្បីទឹងយកចំណេញកប់ក្តោង ៗ គេឲ្យឈ្នួលទុគិតសម្រាប់ឲ្យតែអ្នកកម្មកររស់ទាំងត្រដររមាន-កម្លាំងល្មមតែស្អែកឡើងទៅធ្វើការឲ្យមេទុនទៀតប៉ុណ្ណោះ ៗ ដោយសារតែកម្មកររវេទនាពេកបានជាគេឃើញនៅបណ្តា-ប្រទេសមូលធនិយម កម្មករតស៊ូតក៏ទឹងមេទុន ដើម្បីទាម-ទារបៀវត្សគ្រប់គ្រាន់ទឹងរស់នៅជាមនុស្ស ៗ ក្នុងការតស៊ូតក៏ទាមទាររស់នៅឲ្យបានសមរម្យកុំឲ្យខ្វះមុខខ្វះក្រោយពេក កម្មករតែងតែជួបប្រទះនឹងអំពើឃោរឃៅនៃពួកជិះជាន់សក្តិ-សក្តិនតបមកវិញដោយកម្លាំងប៉ូលិស្តទាហាន ៗ កម្មករ-ឃើញថានៅមុខការឃោរឃៅនៃពួកកាតត្បាតជួរេ្នះ, មានតែសាមគ្គីរវាងអ្នករងគ្រោះជួទុក្ខវេទនាទាំងអស់គ្នាទេ ទើបប្រឡេះបានកម្រៃខ្លះពីឈ្មោះមេទុន ៗ សហជីពជាអង្គការមួយមានសារៈសំខាន់ណាស់សម្រាប់នាំកម្មករតយុទ្ធការពារសិទ្ធិរបស់ខ្លួន ទឹងរស់នៅឲ្យបានសមល្មមទឹងកម្លាំងដែលខ្លួន

ចាយវាយដើម្បីបង្កើតផល ៗ

ដូចបានពណ៌នាពីខាងលើ សមភាពក្នុងឋានៈជាពលរដ្ឋ និងសមភាពក្នុងកិច្ចផលិតកម្ម មិនមែនពេញបរិបូណ៌ទេក្នុងរបបមូលធនិយម ដោយមានការបំពាររំលោភពីអ្នកជិះជាន់ទៅលើអ្នកណា បើមិនមែនអ្នកដែលគេត្រូវជិះជាន់នុះទេ! ជនពួកក្រោយនេះ ដើម្បីនឹងការពារសិទ្ធិរបស់ខ្លួនត្រូវសាមគ្គីគ្នារួមជាបាច់បង្កើតសហជីពធ្វើបាតុកម្មកូដកម្មជាដើម ៗ

ហេតុដូច្នេះហើយបាននៅបណ្ដាប្រទេស ប្រកាន់របបប្រជាធិបតេយ្យរដ្ឋសភាគេឃើញមានអង្គការប្រជាធិបតេយ្យផ្សេងៗ សំរាប់ការពារប្រយោជន៍នៃអ្នកធ្វើការងារដូចជាសហជីព និងសមាគមវិជ្ជាជីវៈឯទៀតៗជាដើម ៗ អង្គការដែលបានពោលមកនេះ មិនមែនកើតឡើងដោយចិត្តល្អស្មោះសរនៃពួកមេទុនកាន់កាប់ការគ្រប់គ្រងប្រទេសនោះទេ គឺកើតមានឡើងដោយសារកម្លាំងតស៊ូតវ៉ានៃអ្នកធ្វើការងារដែលបង្ខំឲ្យមេទុនត្រូវទទួលស្គាល់សិទ្ធិនៃអ្នកត្រូវគេជិះជាន់ឲ្យមានអង្គការសម្រាប់ការពារ

ប្រយោជន៍ពួកខ្លួន ៗ នេះជាដំណើរសង្គមជាក់ស្ដែង បង្ហាញមេរៀនឲ្យកម្មករឃើញ ឃើញថាមានតែកម្លាំងខ្លួនទេ ដែលអាចរំដោះខ្លួនបាន ឯកម្លាំងនោះឯងទៀតគឺកម្លាំងតស៊ូជាសកម្ម មិនមែនកម្លាំងបញ្ញើ យំស្រែកអង្វរករ សង្ឃឹមលើចិត្តសទ្ធាល្អនៃពួកមេទុនសោះឡើយ ម្យ៉ាងទៀត កម្លាំងកម្មករនឹងបានទៅជាកម្លាំងមានផល លុះណាតែកម្លាំងនេះនៅផ្គុំគ្នាជាបាច់មានអង្គការនាំមុខប្ដូរផ្ដាច់ដែលមានទ្រឹស្ដីត្រឹមត្រូវជាមូលដ្ឋាននៃកិច្ចប្រតិបត្តិការ ពីព្រោះដំណើរសង្គមដើរទៅតាមលំអាននៃច្បាប់ធម្មជាតិរបស់វាពុំអាចឃាត់បានឡើយ ៗ

គោលការណ៍ទី ៣ នៃលទ្ធិប្រជាធិបតេយ្យ គឺយុត្តិធម៌ ៗ

ក– យុត្តិធម៌ គោលការណ៍យុត្តិធម៌នេះ គេច្រើនតែពុំសូវនឹកនាដល់វាទេ ក្នុងគំនិតនៃលទ្ធិប្រជាធិបតេយ្យ ៗ កាលណាគេនិយាយអំពីលទ្ធិប្រជាធិបតេយ្យ គេសំដៅតែត្រង់សេរីភាពនឹងសមភាពដែលយើងបានអធិប្បាយពីខាងលើ

រួចមកហើយ ។ សេរីភាពទាំងសមភាពមិនទាន់គ្រប់លក្ខណ នៃលទ្ធិប្រជាធិបតេយ្យបានទេ ត្រូវមានវត្ថុធាតុយុត្តិធម៌ទៀត ទើបបានពេញលេញ ។ យើងនឹងពិនិត្យយុត្តិធម៌ក្នុងពីរនាទី ៖ សង្គមកិច្ច និងច្បាប់ ។

១– ក្នុងនាទីសង្គមកិច្ច, យុត្តិធម៌ស្ថិតលើការដែលសិទ្ធិត្រូវឲ្យ បានដល់ពលរដ្ឋទាំងអស់គ្នាជាទូទៅ ។

លទ្ធិប្រជាធិបតេយ្យសំខាន់ ៗ ដូចជាសិទ្ធិក្នុងការបោះពុម្ពផ្សាយ, ប្រជុំគ្នា ។ល។ មិនត្រូវគ្រាន់តែឲ្យមានកត់ចុះក្នុងឯកសារសម្រាប់រដ្ឋប៉ុណ្ណោះទេ អ្នកកាន់កាប់រដ្ឋ ត្រូវចាត់វិធានការណ៍យ៉ាងណា ឲ្យទាល់តែសិទ្ធិទាំងនេះបានទទួលការប្រតិបត្តិជារូបី ដោយធ្វើអនុគ្រោះសព្វបែបសព្វយ៉ាង ។ ឧទាហរណ៍ ៖ ដើម្បីនឹងបោះពុម្ពផ្សាយបានតម្បងបង្អស់សាមីខ្លួនត្រូវមានតម្រិះវិជ្ជាដ៏ហោចណាស់ក៏គង់ចេះអានចេះសរសេរដែរ ។ រដ្ឋាភិបាលត្រូវពង្រីកការសិក្សាជាតិឲ្យបានទូលំទូលាយ បង្កើតសាលារៀនឲ្យមានច្រើន

សម្បូណ៌ ឲ្យអាហារូបករណ៍ដល់សិស្សានុសិស្សគ្រប់ប្រភេទ សង់បណ្ណាល័យ បោះពុម្ពសៀវភៅរៀនសូត្រឲ្យមានបរិបូរណ៌ ៗ ល ៗ បើពុំដូច្នេះទេ ចំនួនអ្នករៀនសូត្របានតិចណាស់ ហើយសិទ្ធិក្នុងការបោះពុម្ពផ្សាយក៏ពុំបានជ្រាបដល់ប្រជាជនទូទៅ នឹងសន្មតទុកថាមានយុត្តិធម៌ពុំបាន ៗ មិនតែប៉ុណ្ណោះ អ្នកមានតំរេះហើយ ត្រូវមានទ្យូវដែនទូវមធ្យោបាយគ្រប់គ្រាន់ នឹងប្រើប្រាស់តំរេះខ្លួនទៀត បើពុំនោះសោតមានតែអ្នកមានទ្រព្យមួយក្តាប់ប៉ុណ្ណោះឯង ដែលអាចប្រើតំរេះរបស់ខ្លួនបានការ ៗ រដ្ឋាភិបាលត្រូវរិះរកវិធានការណ៍យ៉ាងណាឲ្យបានបំពេញលក្ខខណ្ឌនេះទៀត ទើបមានយុត្តិធម៌ ដូចជាបង្កើតរោងពុម្ពជាតិ នឹងអគ្គការជាតិសម្រាប់ចែកចាយក្រដាស ទឹកខ្មៅឲ្យមានតម្លៃឲ្យល្មមនឹងសន្ទុសថវិកាជនធម្មតា ៗ ឧទាហរណ៍មួយទៀត៖ ការប្រជុំគ្នានឹងធ្វើបានឡើងអាស្រ័យមានមធ្យោបាយនឹងសម្ភារៈគ្រប់គ្រាន់ដែរ ដូចជាផ្សាយដំណឹងប្រជុំដល់សាធារណជន គ្រឹស្ថានសម្រាប់ប្រជុំ ៗ ល ៗ ដើម្បីនឹង

ផ្សាយដំណឹងនឹងដល់ទីកន្លែងប្រជុំគឺសុទ្ធតែត្រូវការតា "ប្រាក់" ទាំងអស់ ។ ម្ល៉ោះហើយជនធម្មតាដែលគ្មានកញ្ច្រាសនាល្អ កើតមកជាចៅតា "ប្រាក់" នោះពុំអាចនឹងប្រើសេរីភាពប្រជាធិបតេយ្យនេះបានឡើយ ។ នេះសរឲ្យឃើញថាយុត្តិធម៌ក្នុងនាទីសង្គមកិច្ចមានតែនៅលើក្រដាស ឬនិយាយម្យ៉ាងទៀតក៏ត្រូវណាស់ដែរ មានតែសំរាប់ចៅៗតា "ប្រាក់" ពោលគឺជនមួយក្តាប់រាប់ទឹងម្រាមដៃបាន, ក្រុមនុជាសេនៃយុត្តិធម៌ បំណែកឯជនធម្មតារាប់លាននាក់ ត្រូវច្រានចោលក្រៅក្របខណ្ឌប្រើសិទ្ធិប្រជាធិបតេយ្យ ។

២— ក្នុងនាទីច្បាប់ តាមអត្ថន័យ ច្បាប់គឺជាសំនួននៃឆន្ទៈរបស់ប្រជាជាតិ ។ ក្នុងអត្ថន័យតូចមួយយើងនេះ យើងមិនពិនិត្យបញ្ហាប្រជាជាតិ ឲ្យជ្រៅជ្រះទេ យើងគ្រាន់តែជំរាបថាក្នុងសង្គមមានវណ្ណៈប្រជាជាតិគឺមិនមែនជាន់ថ្នាក់ទេ ពួកនោះឬបក្សណាទេ ។ ប្រជាជាតិគឺទាំងអស់ប្រជុំផ្តុំគ្នាឡើង ។ ប្រកបទៅដោយយុត្តិធម៌ ច្បាប់ត្រូវធ្វើសម្រាប់ប្រយោជន៍នៃ

ភាគច្រើន ៗ វិសេសវិសាលណាស់ បើសិនជាប្រយោជន៍នៃភាគនីមួយៗស្របនឹងប្រយោជន៍រួម, តែដោយអពមង្គលមិនមែនដូច្នេះឡើយ ។ ដូច្នោះហើយច្បាប់ត្រូវបំរើប្រយោជន៍នៃភាគច្រើន ៗ នេះគឺជាគំនិតដើមនៃលទ្ធិប្រជាធិបតេយ្យ ចំពោះគោលការណ៍យុត្តិធម៌ ៗ ប៉ុន្តែពួកមេទុនក្រោយដែលបានកាន់កាប់អំណាចស៊ប់កាលណា ឈ្លើងនឹងដើងពោលទៅគំនិតសុចរិតល្អបរិសុទ្ធនេះ ៗ ដោយដំណើរសេដ្ឋកិច្ច ពួកមេទុនប្រែក្លាយទៅជាសត្រូវនឹងសម្ពន្ធមិត្តរាពីមុនវិញ កាលនៅក្រោមការជិះជាន់នៃពួកសក្តិភូមិទាំងអស់គ្នាពោលគឺកម្មករកសិករ ៗ

ក្នុងលក្ខខណ្ឌសេដ្ឋកិច្ចមូលធននិយម កម្មករ កសិករប្រមូលបានជាភាគច្រើនចំណែកឯមេទុនជាភាគតិច ៗ បើអនុវត្តន៍គំនិតល្អបរិសុទ្ធនេះ មេទុនអ្នកជិះជាន់គេលែងធ្វើជាឈ្លើងទៀតបានហើយ ៗ ហើយដើម្បីរក្សាភាពខ្លួនជញ្ជក់ឈាមគេដោយសុខសាន្តឥតធ្វើការខ្លួនឯងនោះ ពួកនេះប្រើកម្លាំងរដ្ឋដែលខ្លួនកាន់កាប់ គឺកម្លាំងទាហាន

ប៉ូលិស ។ ច្បាប់សម្រាប់រដ្ឋតាំងប៉ុន្មាន គេអនុវត្តតែរៀងគ្នា គេ ហើយគេបង្កើតច្បាប់ផ្សេង ៗ ទៀតសម្រាប់បង្ក្រាប នឹងរឹតត្បិតសកម្មភាពតយុទ្ធនៃវណ្ណៈ កម្មករ កសិករ ។ អ្វី ៗ ដែលគេធ្វើបាន កម្មករ កសិករ ធ្វើមិនបាន ។ អ្វី ៗ ដែលគេធ្វើទៅត្រូវ កម្មករ កសិករធ្វើទៅខុស ។ ច្បាប់សង្គមមូលធននិយម គឺច្បាប់សម្រាប់ការពារទូដែកមេទុន ។

សេចក្ដីសន្និដ្ឋាន: ក្នុងសេចក្ដីអធិប្បាយរបស់យើងរៀង ៗ ជាលំដាប់មក យើងបានបង្ហាញឲ្យឃើញថា: របបគ្រប់គ្រង ឬលទ្ធិណាមួយត្រូវមានឡើងស្របនឹងទម្រង់សេដ្ឋកិច្ច គ្រានុះហើយថាលទ្ធិកើតចេញមកពីផ្ទៃសេដ្ឋកិច្ចជានិច្ចកាល គឺពិតជាមិនមែនលទ្ធិបង្កើតសេដ្ឋកិច្ចនោះឡើយ ។ ឯដំណើរសេដ្ឋកិច្ចនោះទៀត ពួកមេទុនមិនអាចឃាត់រាំងមិនឲ្យឈានចំរើនជឿនលឿនទៅមុខបានទេ ពីព្រោះច្បាប់ទូទៅរបស់មូលធននិយម គឺគេចំណេញឲ្យបានកាន់តែច្រើនឡើង ៗ ហើយដើម្បីឲ្យបានចំណេញកាន់តែច្រើនត្រូវតែបង្កើតផលឲ្យ

បានច្រើន ទាំងលក់ឲ្យគេនៅតែបានថ្លៃផង ដោយបន្ថយបំណាយឲ្យបានយ៉ាងតិចក្នុងកិច្ចផលិតកម្មដូចជា ប្រើកម្មករបំនួនតិចឬបញ្ចុះបៀវត្សជាដើម ៗ ដើម្បីនឹងសម្រេចបំណងដំណោកនេះបាន មេទុនរិះរកមធ្យោបាយគ្រប់យ៉ាងដែលសំខាន់ ៗ មានបី៖

១ – ធ្វើឲ្យមាស៊ីនបង្កើតផលកាន់តែល្អពិសេសឡើង

២ – ប្រជេញប្រជែងមេទុនឯទៀត ៗ ឲ្យរលំអស់ នៅសល់តែមេទុនធំ ៗ ពីរ-បី ទើបងាយស្រុះស្រួលគ្នាដើម្បីដាក់កំណត់ថ្លៃទំនិញ,

៣ – រកផ្សារលក់ដូរនៅបណ្ដាប្រទេសអាណានិគម ៗ

ព្រោះហេតុដូច្នោះហើយបានជាមេទុនមិនអាចឃាត់ដំណើរសេដ្ឋកិច្ចកុំឲ្យលឿនទៅមុខបាន ៗ ហើយដកបណាតែសេដ្ឋកិច្ចបានចំរើនណាស់ទៅហើយ វាពុំអាចស្ថិតក្នុងក្របខណ្ឌចង្អៀតចង្អល់នៃលទ្ធិឬរបបចាស់បានឡើយ ការបដិវត្តន៍ក៏ត្រូវតែមានធ្វើឡើង ដើម្បីផាត់ទម្លាក់លទ្ធិនិងរបបចាស់

ទោលហើយទទួលលទ្ធិនីវេបបថ្មីវិញ ដែលស្របទីនគំរិត សេដ្ឋកិច្ចថ្មី ៗ

លទ្ធិថ្មី វេបបថ្មី បំរើប្រយោជន៍នៃកម្មាំនបដិវត្តន៍ដែល ទើបតែនឹងមានជ័យជំនះថ្មី ៗ គឺនសង្គមសក្តិភូមិ កម្លាំង បដិវត្តន៍គឺវណ្ណៈធនិកវេបរ្ទមនីនវណ្ណៈកម្មករ-កសិករ ៗ កម្លាំង បដិវត្តន៍នេះទាក់ទោលនៅវេបបសក្តិភូមិ ដើម្បីអនុវត្តន៍វេបបប្រ-ជាធិបតេយ្យអាស្រ័យសភាជាតិ៖ វេរួសតាទីនក្រុមប្រឹក្សាព្រះ ពជអាណាចក្រ ៗ ប៉ុន្តែក្រោយមកពួកធនិកប្រែក្លាយជាមេទុន ពួកមេទុនមិនតាចហ៊ានហិហា អនុវត្តន៍លទ្ធិប្រជាធិបតេយ្យ បំពោះកម្មករ កសិករឡើយ ៗ ពីព្រោះឥឡូវនេះប្រយោជន៍ មេទុនផុយស្រឡះពីប្រយោជន៍នៃកម្មករ កសិករ ៗ ម៉្លោះ ហើយគេអនុវត្តន៍លទ្ធិប្រជាធិបតេយ្យតែវវាំងពួកគេគ្នាគេមួយ គាប់ បំណែកឯកម្មករ កសិករ រាប់លានទាក់ ស្គាល់លទ្ធិ-ប្រជាធិបតេយ្យតែនៅលើក្រដាសឯកសារ ដូចជាយើងបាន វែកញែកពីខាងលើស្រាប់ ៗ ព្រោះហេតុនេះបានជាគេហៅ

លទ្ធិប្រជាធិបតេយ្យ ក្នុងរបបមូលធននិយមថា៖ « លទ្ធិប្រជា-ធិបតេយ្យសភានិយម ឬលទ្ធិប្រជាធិបតេយ្យធនិក » បានសេចក្តីថា លទ្ធិប្រជាធិបតេយ្យសម្រាប់ពួកធនិកមួយក្តាប់ ៗ រដ្ឋសភា និងក្រុមប្រឹក្សាព្រះរាជអាណាចក្រ បែរទៅជាគិតតែបំរើប្រយោជន៍ធនិក ដោយពួកនេះជាអ្នកមានកម្លាំងអំណាចគ្រប់គ្រង បានរិះរកមធ្យោបាយបញ្ជូនតំណាងពួកខ្លួនពេញសភាទាំងពីរ ៗ គេឃើញអ្នកតំណាងរាស្ត្របំរើប្រយោជន៍ធនិក ប្រើគ្រប់កលឧបាយ ដើម្បីជិះជាន់កម្មករ កសិករ ៗ មួយពួកតាំងខ្លួនជាអ្នកពាតក្បាតចំហរមុខ មួយពួកទៀតលាក់មុខអាក្រក់ពិតប្រាកដរបស់ខ្លួនធ្វើពុត ជាអ្នកខ្នះខ្នែងរកផលប្រយោជន៍ឲ្យដល់ កម្មករ កសិករ ដើម្បីនឹងបោកបញ្ឆោតពួកនេះឲ្យជឿតាម ឯការពិតគឺនាំឲ្យកម្មករ កសិករ វិលវល់វង្វេងរកផ្លូវបម្រះខ្លួនឲ្យរួចពីក្រញាំដៃធនិកមិនឃើញ ៗ អ្នកបំរើកម្មករ កសិករ ក្នុងក្បាយបន្ទំនេះ ដើម្បីនឹងសម្រេចនយោបាយលាក់ពុតរបស់ខ្លួនបាន គឺប្រើកម្លាំងទឹកប្រាក់

វិញកម្មករ កសិករ មួយស្រទាប់លើបង្ខូចគំនិតមារយាទពួកនេះ ដែលស្រវឹងនឹងប្រយោជន៍ផ្ទាល់ខ្លួន ឲ្យជួយណែនាំបញ្ចុះបញ្ចូលបណ្ដាកម្មករ កសិករ ដែលលំបាកវេទនា ឲ្យសុខចិត្តទ្រាំទ្ររបបពុករលួយ ។

ប៉ុន្តែទោះយ៉ាងណាក៏ដោយ សេចក្ដីសុចរិតគង់តែនឹងបានលូតលេចឡើងឲ្យក្នអ្នកផងបានឃើញច្បាស់ពុំខាន ៗ អំពើទុច្ចរិតអយុត្តិធម៌តែងតែចាញ់អំពើសុចរិតសប្បុរសធម៌ជានិច្ច ។

ហេតុដូច្នេះយើងត្រូវសង្ឃឹមលើជ័យជំនះនៃកម្មករ កសិករ ពីព្រោះកម្មករ កសិករ គឺជាកម្លាំងពិតប្រាកដនៃប្រជាជាតិ ហើយម្យ៉ាងទៀត កម្មករ កសិករ អនុវត្តន៍ទ្រឹស្ដីវិទ្យាសាស្ត្រ ដើម្បីដោះស្រាយបញ្ហាសង្គម ។

ហេតុអ្វីបានជាយើងហ៊ានថាកម្មករ កសិករ គឺជាកម្លាំងពិតប្រាកដនៃប្រជាជាតិ ? ពីព្រោះ កម្មករ កសិករ នេះហើយដែលជាអ្នកបង្កើតផល ។ គ្មានកម្មករ កសិករ

សេដ្ឋកិច្ចមិនអាចមានដំណើរបានឡើយ ។ កសិករជាអ្នកបង្កើតផលដំណាំដាំដុះសព្វសារពើ មិនមែនអ្នកឯណាទៀតក្រៅអំពីជនជំពូកនេះទេ ដែលគាស់ក្ការភ្ជួរស្រែដាំចំការ ។ កម្មករជាអ្នកបង្កើតផលក្នុងរោងចក្រនឹងកម្មន្តសាលគ្រប់យ៉ាង គ្មានជនជំពូកនេះ របស់ប្រើប្រាស់នឹងគ្រឿងបរិភោគឧបភោគមិនអាចនឹងកើតបានឡើយ ។ នេះគឺការពិតប្រាកដក្នុងនាទីសេដ្ឋកិច្ច ។ បែរទៅក្នុងនាទីកម្លាំងយោធាវិញក៏ដូច្នោះដែរ ៖

មានតែកូនកសិករនឹងកម្មករទេ ដែលជាអ្នកកាន់កាំភ្លើង ក៏កើតជាកងទ័ពរក្សាការពារមាតុភូមិ ។ ឃើញថាកម្លាំងពិតប្រាកដនៃប្រជាជាតិស្ថិតលើកម្មករ-កសិករ ។ ការណ៍នេះជាការពិតប្រាកដមានហើយ ប៉ុន្តែក្នុងរបបមូលធននិយមពួកមេទុនជាអ្នកទាញខ្សែបណ្ដៀរ ។ ដើម្បីកុំឲ្យពួកគេនេះញាក់បានតាមចិត្តត្រូវតែយើងកម្មករ-កសិករដឹងខ្លួនផង ។ លក្ខខណ្ឌមួយទៀត ត្រូវតែកម្មករកសិករជឿនៅលើកម្លាំង

ខ្លួនឯងផង ហើយត្រូវជាក់ច្បាស់ក្នុងចិត្តថា មានតែខ្លួនទេដែលអាចលោះទុក្ខខ្លួនបាន គ្មានជនឯណាមកជួយខ្លួន ឲ្យបានសម្រេចទីបំផុតបានឡើយ ។ ការជំនឿខ្លួនភ្ញាក់សតិសម្បជញ្ញៈនៃកម្មករ-កសិករនេះ មិនមែនមានឡើងដោយឯងៗទេ ត្រូវមានការអប់រំឲ្យជានិរន្តរ ហើយមានការពិសោធន៍ជាក់ស្តែងខ្លួនឯងទៀតផង ។ ត្រង់នេះហើយបានជាទ្រឹស្តីបដិវត្តន៍នឹងការរៀនសូត្រប្រវត្តិសាស្ត្រ នៃប្រទេសដទៃ ត្រូវតែមានជាការចាំបាច់ណាស់ ដើម្បីកុំឲ្យកម្មករ កសិករ រវើរវាយគ្មានសតិអារម្មណ៍នឹងនួនជាក់ច្បាស់ប្រាកដ ។ ការប្រតិបត្តិអត់ទ្រឹស្តីសន្មតជាដូចខ្វាក់ ឯទ្រឹស្តីអត់ការប្រតិបត្តិ ទុកដូចជាបង្កួតទទេ គ្មានគួរទេះ ។ បានសេចក្តីថា: មួយអត់មួយប្រើការមិនបានផល ។ ទ្រឹស្តីត្រូវមានការប្រតិបត្តិមកបំពេញការប្រតិបត្តិត្រូវបានពន្លឺបំភ្លឺដោយទ្រឹស្តី ។

កម្មករ កសិករ គឺជាកម្លាំងជាតិ ប៉ុន្តែបើនៅកត់កយមួយទីទៃពីមួយ កម្លាំងនោះមិនខ្លាំងបានទេ ប្រៀបដូចជា

ចង្កឹះមួយ ៗ ពីគ្នា កាច់បំបាក់បានស្រួលណាស់ ៗ បើចង់កុំឲ្យកាច់បាក់ ត្រូវចងផ្តុំគ្នារាប់ចាប់ឡើង ៗ កម្មករ កសិករ ចងផ្តុំគ្នាម្តេចបាន? បានអ្វីធ្វើជាចំណង? ចំណងនេះគឺអង្គ-ការចាត់តាំងដូចជាសហជីព, សហករណ៍, សមាគមផ្សេងៗ ជាដើម ៗ

ហេតុដូច្នេះ កម្មករ កសិករ បើចង់រំដោះខ្លួនឲ្យរួចពីការជិះជាន់នៃមូលធនទិយម ត្រូវតែប្រមូលផ្តុំគ្នាឡើងក្នុងអង្គការចាត់តាំងណាមួយ ដែលមានទិសដៅដើម្បីប្រយោជន៍ប្រជាជនពិត ៗ ហើយមានទ្រឹស្តីស្របតាមវិទ្យាសាស្ត្រជាមូលដ្ឋានដើម្បីប្រតិបត្តិការ ៗ អង្គការចាត់តាំងដែលបំរើប្រយោជន៍ប្រជាជនពិត ៗ ត្រូវតែអង់អាច ហើយមានកម្មវិធីច្បាស់លាស់ ៗ អង្គការនេះ ត្រូវនៅពីខាងមុខមហាជនជានិច្ច ដើម្បីនឹងជួយតម្រែតម្រង់ប្រជាជនមហាជន ៗ វាត្រូវនៅជិតស្និទ្ធនឹងប្រជាជន, ស្គាល់បំណងប្រជាជន, ហើយនាំឲ្យតស៊ូតវ៉ា តែត្រឹមកំរិតណា ដែលស្ថានការណ៍ក្នុងប្រទេស

នឹងក្រៅប្រទេស មានអនុគ្រោះឲ្យ ។

មួយយ៉ាងទៀត ហើយជា « ១ » សំខាន់ផង, វាត្រូវយល់ថាវាធ្វើការជាមួយប្រជាជន ហើយដើម្បីប្រជាជន ។ វាមិនត្រូវដើរលឿនហួសប្រជាជន ហើយវាក៏មិនត្រូវនៅពីក្រោយប្រជាជនដែរ ។ វាត្រូវទៅមួយជំហានពីខាងមុខប្រជាជន លឿនឆ្ងាយពេកប្រជាជនតាមមិនទាន់ ។ បើបែរជានៅខាងក្រោយនោះ មិនអាចនឹងដឹកនាំប្រជាជនបានជាដាច់ខាត។ វាត្រូវយល់ស្ថានការណ៍ក្នុងប្រទេសនិងសាកលលោក ហើយត្រូវស្គាល់កម្លាំងសតិអារម្មណ៍ ភ្ញាក់រឭកប្រជាជនដើម្បីនឹងបង្កើតហេតុទាំងពីរនេះឲ្យស្របគ្នា កុំឲ្យមានការអន្តរាយ ឥតប្រយោជន៍ដល់ប្រជាជន ។

រួមសេចក្ដីមក កម្មករ កសិករ ជាកម្លាំងនៃប្រជាជាតិពិតប្រាកដ ប៉ុន្តែកម្លាំងនេះនឹងសម្រេចការបានផលល្អ លុះត្រាណាតែមានការអប់រំ ដឹកនាំស្របតាមកាលៈទេសៈ

ស្របតាមដំណើរសង្គមដែលការបង្កើតផល សេដ្ឋកិច្ចសម្រាប់រស់នៅជាមាស៊ីនជម្រុញ ។

( ចប់ )

X

X X

រោងពុម្ពយុវពាណិជ្ជ